00250413

C22/5/1

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ១៧) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / DEC / 2008
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fay

## បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេច អំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

**អ្នកដាក់ឯកសារ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ សេចក្តីបញ្ជាក់ (Certified Date/Date de certification): 11 / DEC / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fay

**អ្នកទទួលឯកសារ៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

## I. សេចក្តីផ្តើម

អនុលោមតាមវិធាន ៦៣ (៧) និងវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក "វិធានផ្ទៃក្នុង" មេធាវីការពារក្តី បានដាក់បណ្តឹងឧទ្ធរណ៍នេះ ប្រឆាំងនឹង "ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" (ដីកាសម្រេចអំពីការបន្តថេរៈវេលា) ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨[1]។ នៅក្នុងដីកាសម្រេចអំពីការបន្តថេរៈវេលា ក.ស.ច.ស បានសម្រេចថា ការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់ ពីព្រោះវាមានហេតុផលសមស្រប ដែលអាចនាំឲ្យជឿបានថាលោក **អៀង សារី** បានប្រព្រឹត្តបទឧក្រិដ្ឋដែលលើកឡើងនៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន[2] និងលក្ខខណ្ឌចំនួនបី ក្នុងចំណោមលក្ខខណ្ឌទាំងប្រាំដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) ត្រូវបានបំពេញ ដោយវិធាននេះចែងថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បីធានានូវវត្តមានរបស់លោក **អៀង សារី**, ការពារសន្តិសុខឲ្យជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ក.ស.ច.ស យល់ឃើញថា វិធានផ្ទៃក្នុង មិនមានចែងអំពីទម្រង់ឃុំខ្លួនផ្សេងទៀតទេ និងបានបកស្រាយសំណើសុំរបស់លោក **អៀង សារី** ឲ្យឃុំខ្លួនក្នុងផ្ទះ ជាសំណើសុំឲ្យដោះលែងជនត្រូវចោទទៅវិញ។ ដោយសារ ក.ស.ច.ស កំណត់ថា គោលបំណងរបស់វិធាន ៦៣(៣)(ខ) មានស្មារតីតម្រូវឲ្យឃុំខ្លួនបន្ត ដូច្នេះសហចៅក្រមស៊ើបអង្កេតបានសម្រេចថា ការឃុំខ្លួននៅក្នុងផ្ទះមិនអាចផ្តល់ឲ្យនោះទេ។

## II. សេចក្តីសង្ខេបនព្វហេតុ

១. មេធាវីការពារក្តីនឹងបង្ហាញភស្តុតាងថា៖

---

[1] *រឿងក្តីលោក **អៀង សារី*** សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨។

[2] *រឿងក្តីលោក **អៀង សារី*** សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧។

ក. ការស៊ើបអង្កេតមិនបានធ្វើឡើងដោយយកចិត្តទុកដាក់ និងសិទ្ធិមនុស្សជាសារវ័ន្តរបស់លោក **អៀង សារី** មិនត្រូវបានគោរពគ្រប់គ្រាន់នោះទេ។

ខ. ក.ស.ច.ស មានភារកិច្ចរកភស្តុតាង ដើម្បីបង្ហាញថា លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) និង(ខ) ត្រូវបានបំពេញ។

គ. ការខកខានមិនបានបន្ថែមភស្តុតាងទៅក្នុងសំណុំរឿង គឺមិនបានធ្វើឱ្យអ្នកអង្កេតសមហេតុផលម្នាក់ជឿថា កំរិតនៃភស្តុតាងដូចដែលបានចែងដោយវិធាន ៦៣(៣)(ក) ត្រូវបានបំពេញឡើយ។

ឃ. ការបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង គឺជាការមិនចាំបាច់ ពីព្រោះ (ក) ការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង មិនមែនជាទម្រង់តែមួយគត់ក្នុងការឃុំខ្លួន ដែលវិធានផ្ទៃក្នុងអនុញ្ញាតនោះទេ និង (ខ) លក្ខខណ្ឌសមហេតុផលនៃការដាក់ឃុំនៅក្នុងផ្ទះ ក៏ជាជម្រើសដែល ក.ស.ច.ស គួរលើកមកពិចារណាដែរ

ង. ការឃុំខ្លួនក្នុងផ្ទះដែលមានលក្ខខណ្ឌសមហេតុផល ពិតជាវិធានការការពារគ្រប់គ្រាន់តាមគោលបំណង ដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)។

## III. ច្បាប់

២. វិធាន៦៣(៣) ចែងអំពីលក្ខខណ្ឌចំនួនពីរ ក្នុងការអាចសម្រេចចេញដីកាឃុំខ្លួនបណ្តោះអាសន្ន។ ជាពិសេស វិធាន៦៣(៣)(ក) តម្រូវថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដែលបានចោទប្រកាន់។ និង វិធាន៦៣(៣)(ខ) ចែងថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីបំពេញលក្ខខណ្ឌមួយ ក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ៖ (i) រារាំងកុំឱ្យជនត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋ, (ii) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង (iii) រារាំងហានិភ័យលួចរត់របស់ជនត្រូវចោទ, (iv) ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ (v) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

៣. វិធាន ៦៣(៣) គឺមានលក្ខណៈឆន្ទានុសិទ្ធិ ដូចដែលបានបង្ហាញតាមរយៈនៃការប្រើពាក្យពេចន៍ថា៖ "[ក.ស.ច.ស] *អាច*ចេញដីកាឃុំខ្លួនបណ្តោះអាសន្ន *លុះត្រាតែ* [មានបញ្ជាក់បន្ថែម] នៅពេល [...] លក្ខខណ្ឌនានាត្រូវបានបំពេញ"។ ទោះបីជាលក្ខខណ្ឌទាំងអស់នៅក្នុងវិធាន ៦៣(៣) ត្រូវបានបំពេញហើយក៏ដោយក៏ ក.ស.ច.ស មានអំណាចឆន្ទានុសិទ្ធិក្នុងការចេញដីកាបង្គាប់ឲ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្នបានដែរ។ វាបានគូសបញ្ជាក់បន្ថែមទៀតថា ការដកហូតសិទ្ធិសេរីភាព អាចធ្វើការពិចារណា លុះត្រាតែលក្ខខណ្ឌនៃវិធានផ្ទៃក្នុង "ត្រូវបានបំពេញ" ដូច្នេះត្រូវតម្រូវឲ្យមានការបង្ហាញភស្តុតាងឲ្យបានច្រើន មុនពេលលក្ខខណ្ឌណាមួយដែលចែងក្នុងវិធានផ្ទៃក្នុង មានសនិទានកម្មចំពោះការឃុំខ្លួនបណ្តោះអាសន្ន។

៤. បន្ថែមលើវិធានផ្ទៃក្នុង អត្ថបទច្បាប់អន្តរជាតិមួយចំនួន បានបង្ហាញអំពីបទដ្ឋាននៃការឃុំខ្លួនបណ្តោះអាសន្ន ដែលតម្រូវដោយច្បាប់អន្តរជាតិ។ ជាពិសេស មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងថា៖

> បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ ត្រូវ [...] មានសិទ្ធិជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួន ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការដោះលែងឲ្យនៅក្រៅឃុំ គឺជាវិធាន ដរាបណាមានការធានាការចូលខ្លួនរបស់ជននោះនៅពេលជំនុំជម្រះ ឬនៅគ្រប់ដំណាក់ការដទៃទៀតនៃដំណើរការនីតិវិធីរបស់តុលាការ [...]។[3]

៥. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានឥទ្ធិពលយ៉ាងច្បាស់លើមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា៖

> "ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ។

[3] សូមមើលផងដែរ មាត្រា១៤(៣)(គ) ដែលចែងអំពីសិទ្ធិ"ត្រូវបានជំនុំជម្រះដោយគ្មានការពន្យាពេលមិនសមហេតុផល"។

៦. មាត្រា៥ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស គឺបានណែនាំ និងរំលឹកឡើងវិញអំពីគោលបំណងដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា៥ បានចែងថា៖

> "១. ជនគ្រប់រូប មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ខ្លួនដូចមាននៅក្នុងករណីដូចខាងក្រោម [...]
> ៣. ជនគ្រប់រូប ដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន [...] ត្រូវមានសិទ្ធិជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែងឱ្យនៅក្រៅឃុំក្នុងពេលកំពុងរង់ចាំជំនុំជម្រះ។ ការដោះលែងឱ្យនៅក្រៅឃុំ អាចត្រូវមានលក្ខខណ្ឌធានាការចូលខ្លួនរបស់ជននោះនៅពេលជំនុំជម្រះ"។

៧. ទោះបីជាអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មិនមែនជាច្បាប់ធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ប៉ុន្តែ បទប្បញ្ញត្តិនេះមានលក្ខណៈស្រដៀងគ្នានឹងបទប្បញ្ញត្តិដែលអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក ដូចជា កតិកា ICCPR ហើយយុត្តិសាស្ត្ររបស់វាត្រូវបានយកជាសំអាងជាញឹកញាប់ដោយ អ.វ.ត.ក[4]។

## IV. ឧឡារិកវណ៌

### ក. ការស៊ើបអង្កេតមិនបានធ្វើឡើងដោយយកចិត្តទុកដាក់ និងសិទ្ធិមនុស្សជាសារវ័ន្តរបស់លោក អៀង សារី មិនត្រូវបានគោរពឲ្យបានគ្រប់គ្រាន់ទេ

៨. ក.ស.ច.ស បានកត់សម្គាល់ថា "ពេលវេលាដែលកន្លងផុតទៅ គឺជាកត្តាមួយសម្រាប់យកមកធ្វើការពិចារណា ដើម្បីសម្រេចពីលក្ខណៈសមស្របនៃការរក្សាការឃុំខ្លួនបណ្តោះអាសន្នរបស់ជន

[4] ទាំង ក.ស.ច.ស និង អង្គបុរេជំនុំជម្រះ បានយោងលើយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សនៅក្នុងឯកសារដែលដាក់កាលពីមុន។ *សូមមើលរឿងក្តីរបស់លោក អៀង សារី* ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ២ ឬដីកាសម្រេចអំពីការបន្តថេរៈវេលា កថាខណ្ឌ៣៧។ និង *រឿងក្តីលោក នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០៩) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ទាក់ទងនឹងលក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្ន កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ១៥។

ត្រូវចោទ"[5] និងថា ការឃុំខ្លួនបណ្តោះអាសន្ននឹងមិនត្រូវបានចាត់ទុកថាមិនត្រឹមត្រូវទេ ប្រសិនបើការស៊ើបអង្កេតបានធ្វើឡើងដោយយកចិត្តទុកដាក់[6]។

៩. ក.ស.ច.ស បានប្រើប្រាស់លក្ខណៈវិនិច្ឆ័យ"ការយកចិត្តទុកដាក់" ដើម្បីសម្រេចថាតើសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្របរបស់លោក **អៀង សារី** ត្រូវបានរំលោភបំពានដែរឬទេ។ ក.ស.ច.ស បានយោងជាខ្លាំងលើយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស ដែលតម្រូវនូវលក្ខខណ្ឌថា "នៅពេលជនជាប់ចោទត្រូវបានឃុំខ្លួន [ជននោះ]មានសិទ្ធិទទួលការស៊ើបអង្កេតរឿងក្តីរបស់ខ្លួនជាអាទិភាព និងធ្វើការស៊ើបអង្កេតដោយមានការយកចិត្តទុកដាក់"[7]។ បន្ថែមពីលើនេះលក្ខខណ្ឌតម្រូវឱ្យធ្វើការស៊ើបអង្កេតតាមផ្លូវតុលាការដោយយកចិត្តទុកដាក់ គឺដើម្បីធានាថាលោក **អៀង សារី** មិនត្រូវបានទទួលរងនូវការខូចខាតដោយគ្មានហេតុផល ខណៈពេលគាត់កំពុងរង់ចាំការបញ្ចប់នូវការស៊ើបសួរ ឬ ការជំនុំជម្រះរបស់ខ្លួន[8]។ ផលប៉ះពាល់នៃការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឱ្យខូចប្រយោជន៍ដល់ជនត្រូវចោទ ត្រូវបានរៀបរាប់យ៉ាងក្បោះក្បាយ។ ការបន្តថេរៈវេលានៃការឃុំខ្លួន គឺបង្កការលំបាកជាច្រើនលើជនត្រូវចោទ និងមានផលប៉ះពាល់មិនល្អចំពោះសុខភាពផ្លូវចិត្តរបស់ជនត្រូវចោទ[9]។ កត្តានានា ដែលនាំឱ្យមានផលប៉ះពាល់នេះ រួមមាន

---

[5] ដីកាសម្រេចអំពីការបន្តថេរៈវេលា កថាខណ្ឌ៣៧។

[6] ដូចខាងលើដែរ។

[7] *រឿងក្តី Matznetter តទល់នឹង ប្រទេសអូស្ត្រាលី* របស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស ពាក្យបណ្តឹងលេខ២១៧៨/៦៤ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៩ កថាខណ្ឌ១២។

[8] *រឿងក្តី Wemhoff តទល់នឹង ប្រទេសអាល្លឺម៉ង់* ពាក្យបណ្តឹងលេខ២១២២/៦៤ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨ កថាខណ្ឌ១៨។

[9] ភាគច្រើន ការមិនអើពើក្នុងការពិចារណាចំពោះការឃុំខ្លួន គឺប៉ះពាល់ដល់ក្រុមគ្រួសាររបស់ជនជាប់ឃុំ សង្គមទាំងមូល អភិបាលកិច្ចរដ្ឋ និងប្រសិទ្ធិភាពនៃការគ្រប់គ្រងវិស័យតុលាការ ដែលបញ្ហាទាំងអស់នេះទទួលឥទ្ធិពលអាក្រក់មកពីការចេញសេចក្តីសម្រេចឱ្យឃុំខ្លួនជនជាប់ចោទមុនពេលជំនុំជម្រះ។ ដូចមានរាយការណ៍នៅក្នុងការប្រកាសផ្សាយថ្មីៗនេះ "សេចក្តីក្នុងការឃុំខ្លួនជនណាម្នាក់ មុនពេលជននោះត្រូវបានរកឃើញកំហុសអំពីការប្រព្រឹត្តបទល្មើស គឺជាសេចក្តីសម្រេចដ៏អាក្រក់ដែលចេញដោយតុលាការ", Martin Schönteich, *ទំហំ និងផលវិបាកនៃការឃុំខ្លួនមុនពេលជំនុំជម្រះជុំវិញសាកលលោក* Justice Initiatives, ការបោះពុម្ពផ្សាយរបស់អង្គការOpen Society Justice Initiative, និទាឃរដូវ ឆ្នាំ២០០៨ ទំព័រ១១ កថាខណ្ឌ១៧។

"ការបង្ខំឲ្យរស់នៅម្នាក់ឯង កង្វះនូវភាពឯកជន កង្វះនូវសកម្មភាពសំខាន់ៗ និងបរិក្ខារផ្នែកស្ថារតីមិនគ្រប់គ្រាន់"[10]។ ភាពមិនច្បាស់លាស់អំពីលទ្ធផលនៃការបន្តការស៊ើបអង្កេត អាចធ្វើឲ្យជនត្រូវចោទទទួលរងនូវការឈឺចាប់យ៉ាងច្រើនដែរ[11]។

១០. នៅក្នុងការពិចារណារបស់សហចៅក្រមស៊ើបអង្កេត លើការអនុវត្តការស៊ើបសួរដោយមានការយកចិត្តទុកដាក់ ក.ស.ច.ស បានយោងយ៉ាងខ្លាំងលើយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស និងបានយល់ឃើញថា វាជាការចាំបាច់ដែលត្រូវគិតដល់ភាពស្មុគស្មាញរបស់ដំណើរការនីតិវិធី និងរឿងក្ដីនេះទាំងមូល នៅពេលពិនិត្យលើការអនុវត្តការស៊ើបសួរ[12]។ គ្មានមូលហេតុណាមួយ បញ្ជាក់ភាពត្រឹមត្រូវនៃការបន្តថេរវេលានៃការឃុំខ្លួននៅក្នុងករណីនេះទេ។ ទីមួយ តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស បានលើកឡើងថា ការស៊ើបសួរត្រូវតែអនុវត្តឲ្យបានឆាប់រហ័ស ទោះបីជារឿងក្ដីមានលក្ខណៈស្មុគស្មាញក៏ដោយ[13]។ ទីពីរ នៅក្នុងរឿងក្ដីនេះ បន្ទាប់ពីស៊ើបសួរអស់រយៈពេលពេញមួយឆ្នាំ ចាប់តាំងពីពេលចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន

---

[10] ដូចខាងលើដែរ កថាខណ្ឌ១៨។

[11] ដូចខាងលើដែរ កថាខណ្ឌ១៩។

[12] ក.ស.ច.ស យោងលើរឿងក្ដីរបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស, *រឿងក្ដីFrydlender តទល់នឹង ប្រទេសបារាំង* ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ ពាក្យបណ្ដឹងលេខ ៣០៩៧៩/៩៦ កថាខណ្ឌ៤៣៖ "រយៈពេលនៃដំណើរការនីតិវិធី"សមហេតុផល" ត្រូវធ្វើការវាយតម្លៃដោយគិតដល់កាលៈទេសៈនៃរឿងក្ដី និងដោយពិចារណាលក្ខខណ្ឌដូចខាងក្រោម៖ ភាពស្មុគស្មាញរបស់រឿងក្ដី, ការប្រព្រឹត្តរបស់ម្ចាស់បណ្ដឹងនិងរបស់អាជ្ញាធរពាក់ព័ន្ធ និងមានផលអាក្រក់អ្វីចំពោះម្ចាស់បណ្ដឹងនៅក្នុងករណីជម្លោះនេះ"។ *រឿងក្ដី Pelissier nig Sassi តទល់នឹង ប្រទេសបារាំង* នៅតុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស ពាក្យបណ្ដឹងលេខ ២៥៤៤៤/៩៤ ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ៧៣ បានសម្រេចបន្ថែមថា "ដោយគិតដល់ការរកឃើញរបស់ខ្លួនថា រឿងក្ដីមានភាពមិនស្មុគស្មាញ និងការប្រព្រឹត្តរបស់ម្ចាស់បណ្ដឹងនៃរឿងក្ដីមានលក្ខណៈសមហេតុផល តុលាការសម្រេចថា គ្មានភាពត្រឹមត្រូវណាមួយសម្រាប់ធ្វើការស៊ើបអង្កេតលើសពីរយៈពេលប្រាំឆ្នាំនោះទេ។ ដូចនឹងការលើកឡើងរបស់គណៈកម្មាធិការ តុលាការយល់ឃើញថា ការពន្យារពេល និងរយៈពេលនៃការអសកម្មភាពក្នុងអំឡុងពេលស៊ើបអង្កេតមានភាពមិនត្រឹមត្រូវ"។

[13] *រឿងក្ដី Assenov តទល់នឹង ប្រទេសប៊ុលហ្គារី* តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្ដឹងលេខ ៩០/១៩៩៧/៨៧៤/១០៨៦ ចុះថ្ងៃទី ២៨ តុលា ១៩៩៨ កថាខណ្ឌ ១៥៧ និង *រឿងក្ដី AFFAIRE DEBBOUB ហៅ Husseini ALI c. តទល់នឹង ប្រទេសបារាំង* ពាក្យបណ្ដឹងលេខ ៣៧៧៨៦/៩៧ ចុះថ្ងៃទី ៩ វិច្ឆិកា ១៩៩៩ (ភាសាដើមជាបារាំង)។

លើកដំបូង[14] ភស្តុតាងបន្តិចបន្តួចតែប៉ុណ្ណោះបានដាក់នៅក្នុងសំណុំរឿង ទាក់ទងនឹងលោក **អៀង សារី** ឬជនត្រូវចោទផ្សេងទៀត[15]។ លើសពីនេះទៅទៀត ការស៊ើបអង្កេត ដែលស្នើឡើងដោយក្រុមមេធាវីការពារក្តីផ្សេងៗ ចៅក្រមស៊ើបអង្កេតមិនបានស្វែងរកនោះទេ[16]។

១១. ការពិនិត្យចំពោះ ការយកចិត្តទុកដាក់ ចំពោះការស៊ើបអង្កេតណាមួយ ត្រូវតែផ្ទៀងផ្ទាត់នឹង ល្បឿននៃការស៊ើបសួររបស់ ក.ស.ច.ស ក្នុងការស្វែងរកទាំងភស្តុតាងដោះបន្ទុកនិងភស្តុតាងដាក់បន្ទុក និងថា តើការស៊ើបសួរទាំងនោះធ្វើឡើងតាមវិធីមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការពន្យារពេលដោយមិនសមហេតុផលចំពោះជនត្រូវចោទឬទេ។ ក.ស.ច.ស មិនអើពើទាល់តែសោះចំពោះការពិនិត្យមើលលើចំណុចដូចដែលបានលើកឡើង។ ផ្ទុយមកវិញ ក.ស.ច.ស បែរជាស្វែររកការ

---

[14] *រឿងក្តីលោក* ***អៀង សារី*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

[15] មេធាវីលោកស្រី **អៀង ធីរិទ្ធ** បានលើកទឡ្ហីករណ៍នៅក្នុងការជំទាស់របស់ខ្លួន នៅក្នុង*សំណុំរឿងលោកស្រី* ***អៀង ធីរិទ្ធ*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ការជំទាស់របស់សហមេធាវីការពារក្តីចំពោះចេតនាបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើលោកស្រី **អៀង ធីរិទ្ធ** ដោយសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ដោយតវ៉ាថា ការស៊ើបសួរមិនបានធ្វើឡើងដោយមានការយកចិត្តទុកដាក់, ក.ស.ច.ស ខកខានមិនបានលើកឡើងនូវទឡ្ហីករណ៍ណាមួយបង្ហាញអំពីកំហុសរបស់លោកស្រី **អៀង ធីរិទ្ធ** និងវិធាន ៦៣(៣)(ក)មិនត្រូវបានបំពេញ។ ក.ស.ច.ស បានច្រានចោលទឡ្ហីករណ៍ទាំងអស់។ នៅក្នុង*រឿងក្តីលោក* ***នួន ជា*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ១៦ បានលើកឡើងថា ភស្តុតាងដែលប្រមូលបានពីមុនមក ទាក់ទងភាគច្រើននឹងស-២១ និងទោះបីជាមានការស៊ើបសួរបន្ថែមមួយឆ្នាំទៀត មានភស្តុតាងរឹងមាំបន្តិចបន្តួចប៉ុណ្ណោះត្រូវបានប្រមូលដើម្បីនាំអោយអ្នកសង្កេតសមហេតុផលម្នាក់ជឿថាមានអង្គហេតុដូចដែលដាក់ដោយ ក.ស.ព នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរមែន។

[16] *រឿងក្តីលោក* ***នួន ជា*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើសុំការបញ្ជាក់សេចក្តីសន្និដ្ឋានតបរបស់ក.ស.ច.ស ចំពោះពាក្យសុំកិច្ចស៊ើបសួរលើកទីពីរ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨។ *រឿងក្តីលោក* ***នួន ជា*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ពាក្យសុំកិច្ចស៊ើបអង្កេតលើកទីបី កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨។ *រឿងក្តីលោក* ***នួន ជា*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ពាក្យសុំកិច្ចស៊ើបអង្កេតលើកទីបួន កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨។ ពាក្យសុំកិច្ចស៊ើបអង្កេតលើកទីប្រាំ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។ *រឿងក្តីលោក* ***នួន ជា*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ពាក្យសុំកិច្ចស៊ើបអង្កេតលើកទីប្រាំមួយ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨។

បន្ទោសចំពោះការខ្វះខាតដំណើរការនីតិវិធីក្នុងការស៊ើបអង្កេត តាមរយៈលើកឡើងថា ការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយ បានធ្វើឲ្យមានការពន្យារពេលនីតិវិធីខ្លះដែរ[17]។ ក.ស.ច.ស មិនអាចសម្អាងលើការអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយរបស់លោក **អៀង សារី** ដើម្បីដកហូតសិទ្ធិជាសារវ័ន្តរបស់លោកក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្របនោះទេ។ យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស បានសម្រេចយ៉ាងម៉ឺងម៉ាត់ថា គ្មានលក្ខខណ្ឌណាមួយតម្រូវឲ្យជននោះជួយក្នុងដំណើរការស៊ើបអង្កេត ដែលទីបំផុតអាចនាំឲ្យមានការជំនុំជម្រះជននោះ និងផ្តន្ទាទោសជននោះបានទេ[18]។

១២. ភាពខ្វះខាតដំណើរការនីតិវិធីស៊ើបអង្កេតក្នុងអំឡុងពេលឆ្នាំមុន បង្ហាញយ៉ាងច្បាស់អំពីភាពខ្វះខាតការយកចិត្តទុកដាក់របស់ ក.ស.ច.ស ដែលនាំឲ្យរំលោភបំពានកាតព្វកិច្ចក្នុងការមានការជំនុំជម្រះ

---

[17] ដីកាសម្រេចអំពីការបន្តថេរះវេលា *ដូចនៅជើងទំព័រលេខ១ខាងលើ* កថាខណ្ឌ៤១។

[18] *រឿងក្តី* Eckle *តទល់នឹង ប្រទេសអាល្លឺម៉ង់* របស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស សំណុំរឿងលេខ ៨១៣០/៧៨ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ កថាខណ្ឌ៨២ តុលាការសម្រេចថា "មាត្រា៦ [សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌] មិនតម្រូវឲ្យម្ចាស់បណ្តឹងសហប្រតិបត្តិការជាសកម្មជាមួយអាជ្ញាធរតុលាការនោះទេ។ គ្មានការស្តីបន្ទោសណាមួយ អាចដាក់ប្រឆាំងនឹងម្ចាស់បណ្តឹងដោយសារតែបានប្រើប្រាស់ពេញលេញនូវដំណោះស្រាយដែលមាននៅក្នុងច្បាប់ក្នុងប្រទេសនោះ"។ *សូមមើលផងដែរ រឿងក្តី Corigliano តទល់នឹង ប្រទេសអ៊ីតាលី* របស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស ពាក្យបណ្តឹងលេខ ៨៣០៤/៧៨ ចុះថ្ងៃទី ១០ ធ្នូ ១៩៨២ កថាខណ្ឌ៤១, ៤២។ *រឿងក្តី Dobbertin តទល់នឹង ប្រទេសបារាំង* ពាក្យបណ្តឹងលេខ ១៣០៨៩/៨៧ ចុះថ្ងៃទី ២៥ កុម្ភៈ ១៩៩២ ទំព័រ ៤៣។ *រឿងក្តី Ledonne តទល់នឹង ប្រទេសអ៊ីតាលី* (លេខ ១) ពាក្យបណ្តឹងលេខ ៣៥៧៤២/៩៧ ចុះថ្ងៃទី ១២ ឧសភា ១៩៩៩ ទំព័រ ២៥។ *រឿងក្តី AFFAIRE SACCOMANNO c. តទល់នឹង ប្រទេសអ៊ីតាលី* ពាក្យបណ្តឹងលេខ ៣៦៧១៩/៩៧ ១២ ឧសភា ១៩៩៩ កថាខណ្ឌ២៤ (ភាសាដើមជាបារាំង) ទំព័រ ២៤។ *រឿងក្តី Barfuss តទល់នឹង ប្រទេសសាធារណរដ្ឋឆែក* ពាក្យបណ្តឹងលេខ ៣៥៨៤៨/៩៧ ៣១ កក្កដា ២០០០ ទំព័រ៨៣។ *រឿងក្តី Yagci និង Sargin តទល់នឹង ប្រទេសទួរគី* ពាក្យបណ្តឹងលេខ ១៦៤១៩/៩០ និង ១៦៤២៦/៩០ ចុះថ្ងៃទី ៨ មិថុនា ១៩៩៥ ទំព័រ ៦៦។ *រឿងក្តី Richet តទល់នឹង ប្រទេសបារាំង* ពាក្យបណ្តឹងលេខ ៣៤៩៤៧/៩៧ ចុះថ្ងៃទី ១៣ កុម្ភៈ ២០០១ កថាខណ្ឌ៧៥ (ភាសាដើមជាបារាំង)។ *រឿងក្តី AFFAIRE DEBBASCH c. តទល់នឹង ប្រទេសបារាំង* ពាក្យបណ្តឹងលេខ ៤៩៣៩២/៩៩ កថាខណ្ឌ៤១ (ភាសាដើមជាបារាំង)។ *រឿងក្តី Nemeth តទល់នឹង ប្រទេសហុងគ្រី* ពាក្យបណ្តឹងលេខ ៦០០៣៧/០០ ចុះថ្ងៃទី ១៣ មករា ២០០៤ ទំព័រ២៩។

ក្នុងរយៈពេលសមស្របមួយ[19]។ នេះបង្ហាញឲ្យកាន់តែច្បាស់ តាមរយៈអាយុ និងសុខភាពមិនល្អរបស់លោក **អៀង សារី** ដែល ក.ស.ច.ស មិនបានពិចារណាឲ្យបានគ្រប់គ្រាន់ចំពោះបញ្ហានេះ ប៉ុន្តែ ក.ស.ច.ស បែជាពិចារណាអំពីអាយុ និងសុខភាពរបស់ប្រពន្ធគាត់ ដែលទាក់ទងនឹងហានិភ័យលួចរត់ទៅវិញ[20]។ ការបន្តពន្យារពេលដើម្បីបញ្ចប់ការស៊ើបសួរ កើតឡើងមកពីភាពអសកម្មរបស់ ក.ស.ច.ស និងដោយសារមូលហេតុនេះ ភាពអសកម្មគួរត្រូវបានចាត់ទុកជាការបង្ហាញភស្តុតាងត្រឹមត្រូវគ្រប់គ្រាន់ ដើម្បីដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។

## ខ. ក.ស.ច.សមានភារកិច្ចរកភស្តុតាងដើម្បីបង្ហាញថា លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) និង(ខ) ត្រូវបានបំពេញ

១៣. លិខិតុបករណ៍សិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីផងនោះ បានលើកឡើងថា ការឃុំខ្លួននៅមុនពេលជំនុំជម្រះ គួរតែធ្វើនៅក្នុងករណីពិសេស ប៉ុន្តែមិនមែនជាវិធាននោះទេ។ មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា បានបង្ហាញអំពីការលើកឡើងនេះ។

១៤. វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ សម្រាប់វិធានការមិនឃុំខ្លួន (វិធានតូក្យូ) ក៏បានចែងថា រដ្ឋាភិបាលគួរតែខិតខំប្រឹងប្រែងដោយសមហេតុផល ដើម្បីជៀសវាងការឃុំខ្លួនមុនពេលជំនុំជម្រះ ដែលមានចែងដូចខាងក្រោមថា៖

---

[19] *រឿងក្តី Kudla តទល់នឹង ប្រទេសប៉ូឡូញ* របស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស សំណុំរឿងលេខ ៣០២១០/៩៦ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០០ កថាខណ្ឌ ១៣១-១៣២៖ "ភាពខ្វះខាតនៃដំណើរការនីតិវិធី នាំឲ្យមានការពន្យារពេលជិតមួយឆ្នាំ ប្រាំបីខែ ដែលការពន្យារពេលនេះ តុលាការមិនបានរកឃើញការបញ្ជាក់គ្រប់គ្រាន់ និងការពន្យារពេលនេះចាត់ទុកមិនបានធ្វើឡើងសមស្របនឹងលក្ខខណ្ឌនៃការស៊ើបអង្កេតដោយយកចិត្តទុកដាក់ ដែលមានចែងក្នុងមាត្រា៦(១) [...]។ ហេតុដូចនេះ តុលាការមិនអាចចាត់ទុករយៈពេលដែលកន្លងផុតក្នុងរឿងក្តីនេះ មានលក្ខណៈសមហេតុផលនោះទេ។ ដូច្នេះ ទង្វើនេះគឺជាការរំលោភបំពានមាត្រា៦(១) នៃអនុសញ្ញានេះ"។

[20] ដីកាសម្រេចអំពីការបន្តថេរៈវេលា *សូមមើលនៅជើងទំព័រលេខ១ខាងលើ* កថាខណ្ឌ២៣។

៦.១. ការឃុំខ្លួនមុនពេលជំនុំជម្រះ ត្រូវប្រើប្រាស់ជាមធ្យោបាយដោះស្រាយចុងក្រោយបំផុត នៅក្នុងដំណើរការនីតិវិធី ដោយពិចារណាយកចិត្តទុកដាក់ចំពោះការស៊ើបអង្កេតបទល្មើសដែលចោទប្រកាន់ និងការពារសង្គមជាតិ និងជនរងគ្រោះ។

៦.២. ជម្រើសឃុំខ្លួនមុនពេលជំនុំជម្រះ ត្រូវប្រើប្រាស់នៅដំណាក់កាលដំបូងតាមតែអាចធ្វើបាន។ ការឃុំខ្លួនមុនពេលជំនុំជម្រះ មិនត្រូវបន្តដោយគ្មានភាពចាំបាច់ក្នុងការសម្រេចគោលបំណងដែលមានចែងនៅក្នុងវិធាន៥.១ និងត្រូវប្រើប្រាស់ដោយក្ដីមេត្តា និងដោយគោរពសេចក្ដីថ្លៃថ្នូរ ដែលមនុស្សម្នាក់ៗមាន។

៦.៣. ជនល្មើសត្រូវមានសិទ្ធិបណ្ដឹងឧទ្ធរណ៍ទៅអាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថភាពឯករាជ្យផ្សេងទៀត ក្នុងករណីជននោះត្រូវបានឃុំខ្លួនមុនពេលជំនុំជម្រះ។[21]

១៥. ប៉ុន្តែ យុត្តិសាស្ត្ររបស់តុលាការ ICTY និងយុត្តិសាស្ត្ររបស់តុលាការពិសេសសៀរ៉ាលេអូន ត្រូវបានយកជាសំអាងជាញឹកញាប់ដោយ ក.ស.ព ដើម្បីអះអាងថា នៅក្នុងច្បាប់អន្តរជាតិ ការឃុំខ្លួនគឺជាវិធាន[22] និងជាបញ្ញ័យ បន្ទុកនៃការបង្ហាញភស្តុតាងត្រូវធ្លាក់មកលើក្រុមចុងចោទ ដើម្បីបង្ហាញថា ហេតុអ្វីការដោះលែងបណ្ដោះអាសន្នគួរត្រូវបានគេសំរេច[23]។ ភាពខ្វះខាតអំណាចបង្ខំក្នុងការអនុវត្តសេចក្ដីសម្រេចរបស់ខ្លួន និងការពឹងផ្អែកតែលើសហប្រតិបត្តិការរបស់រដ្ឋដើម្បីតាមដានជនត្រូវចោទដែលត្រូវដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន បានមានន័យថា ខណៈ

---

[21] ឯកសារពេញលេញទាំងស្រុងមាននៅគេហទំព័រ http://www.unhchr.ch/html/menu3/b/h_comp46.htm។

[22] *រឿងក្ដីលោកស្រី* ***អៀង ធីរិទ្ធ*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស មូលហេតុបន្ថែមរបស់សហព្រះរាជអាជ្ញា គាំទ្រការឃុំខ្លួនបណ្ដោះអាសន្នលើរូប **អៀង ធីរិទ្ធ** (អៀង ធីរិទ្ធ) ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៥។ *រឿងក្ដីលោក* ***អៀង សារី*** សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ២៥។ *រឿងក្ដីលោក* ***នួន ជា*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៣) សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងឧទ្ធរណ៍របស់ **នួន ជា** ស្ដីពីការបន្តរយៈពេលឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ១៥។

[23] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Issa Hassan Sesay និងគូកន* សំណុំរឿងលេខ scsl-2004-15-PT សេចក្ដីសម្រេចទៅលើពាក្យសុំរបស់ Morris Kallon អោយមានការដោះលែងអោយមានការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី ២៣ កុម្ភៈ ២០០៤ កថាខណ្ឌ ២៣ (“សេចក្ដីសម្រេចករណី Sesay”)។

ពេលដែលទទួលយកនូវបទដ្ឋានតាមច្បាប់ (de jure) នៃការដោះលែងមុនការជំនុំជម្រះ តុលាការICTY បានតម្រូវឱ្យមានវិធីដោះស្រាយដោយប្រុងប្រយ័ត្នក្នុងការវាយតម្លៃហានិភ័យលួចរត់របស់ជនត្រូវចោទ[24] ដើម្បីសម្រេចពីបទដ្ឋានតាមអង្គហេតុចំពោះការឃុំខ្លួនមុនពេលជំនុំជម្រះ។ ករណីលើកឡើងនេះ ពិតជាមិនដូចករណីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ ដោយសារតែប៉ូលីស និងអាជ្ញាធរ អ.វ.ត.ក មានអាណត្តិ និងធនធាន ដើម្បីអនុវត្តដីកានានាក្នុងការឃុំខ្លួនជនត្រូវចោទនានា។

១៦. តាមពិត នៅក្នុង*រឿងក្តី Hadzihasanovic* តុលាការICTY បានពិចារណា អស់រយៈពេលយ៉ាងយូរ លើបទដ្ឋានតាមអង្គហេតុ(de facto)ចំពោះការឃុំខ្លួន ប៉ុន្តែជាចុងក្រោយ តុលាការសម្រេចយកគោលការណ៍អន្តរជាតិ ដែលជាគោលការណ៍សន្មតថាគ្មានទោស បើមិនទាន់រកឃើញនូវអំពើពិរុទ្ធ និងបានកំណត់ព្រំដែន ថាជាការរំលោភបំពានលើសិទ្ធិសេរីភាពជាសារវ័ន្ត តែចំពោះកាលៈទេសៈ មួយចំនួនប៉ុណ្ណោះ។ តុលាការក៏បានពិចារណាគោលការណ៍ទូទៅនៃសមាមាត្រភាព ដែលកំណត់ថា "ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ដែលឱ្យអាចប្រើប្រាស់វិធានការមិនសូវតឹងរឹង យើងត្រូវតែប្រើប្រាស់វិធានការនេះ"[25]។ នៅតុលាការICTY បទដ្ឋានតាមអង្គហេតុនៃការឃុំខ្លួនចេញមកពីវិធាននីតិវិធី ដែលចែងថា៖ "បន្ទាប់ពីបញ្ជូនខ្លួនទៅកាន់តុលាការ ជនជាប់ចោទត្រូវបាន

---

[24] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragon Jokic* សំណុំរឿងលេខ IT-02-53-PT សេចក្តីសម្រេចលើសំណើសុំឱ្យដោះលែងជនជាប់ចោទ Jokic នៅក្រៅឃុំបណ្តោះអាសន្ន ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៧។ សេចក្តីសម្រេចនេះមានលក្ខណៈគួរឱ្យកត់សម្គាល់ ដោយសារវាបានបង្ហាញថា ការបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្នលើរូប Dragan Jokic ដោយផ្អែកលើការព្រួយបារម្ភថា នៅពេលនោះ រដ្ឋម្ចាស់ផ្ទះត្រូវបានចាត់ទុកជាផ្នែកនៃប្រទេស Bosnia និង Herzegovina ដូច្នេះរដ្ឋនេះមិនអាចបំពេញកាតព្វកិច្ចពិតប្រាកដដែលតម្រូវដោយតុលាការក្នុងការធានាការវិលត្រលប់ដោយសុវត្ថិភាពរបស់ជនជាប់ចោទ។ ការធានាទាំងនេះ មិនអាចត្រូវបានបំពេញនោះទេ ហេតុដូចនេះសំណើសុំនេះ ត្រូវបានច្រានចោល។ ស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា មានលក្ខណៈខុសគ្នា ហើយអ្នកខ្លះអាចឆ្ងល់ថា តើជនជាប់ចោទច្រើនប៉ុន្មាននាក់អាចនឹងដោះលែងនៅក្រៅឃុំជាបណ្តោះអាសន្ន ប្រសិនបើតុលាការICTY អាចចេញសេចក្តីសម្រេចរបស់ខ្លួនតាមវិធីដ៏ល្អ ដូចមាននៅអ.វ.ត.ក។

[25] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Hadzihasanovic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-01-47 សេចក្តីសម្រេចផ្តល់ការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដល់ Enver Hadzihasanovic ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ កថាខណ្ឌ៧។

ឃុំខ្លួន[26]។ ជាថ្មីម្តងទៀត វិធានអ.វ.ត.ក ត្រូវបានគេពង្រាងដោយមានចេតនាគិតគូរដល់បទដ្ឋានកម្រិតខ្ពស់លើផ្នែកសិទ្ធិមនុស្ស ដែលជនត្រូវចោទទាំងអស់ត្រូវទទួលបាន។ ភាពខ្វះខាតដែលគេឃើញមាននៅក្នុងវិធាន និងយុត្តិសាស្ត្រនៃក្នុងតុលាការបណ្តោះអាសន្ននានា មិនមានកើតឡើងនៅក្នុងវិធាននៃ អ.វ.ត.ក ទេ ។ តាមពិត វិធាន៦៣ ចែងយ៉ាងច្បាស់លាស់អំពីមូលហេតុផ្លូវច្បាប់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ដោយយោងទៅលើលក្ខខណ្ឌផ្សេងៗដែលត្រូវបានបំពេញ។ ការពិចារណាខាងលើនេះ គួរតែទប់ស្កាត់ការរំលោភបំពានពីសំណាក់ ក.ស.ច.ស និងកំណត់ថា ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែស្ថិតនៅក្នុងករណីពិសេស ប៉ុន្តែវាមិនមែនជាវិធាននោះទេ។

១៧. វិធានដំបូងៗនៃតុលាការ ICTY និង តុលាការ ICTR បានផ្ទុកផ្តាក់លើមេធាវីការពារក្តី ដើម្បីបង្ហាញនូវ "កាលៈទេសៈលើកលែងពិសេស" មុននឹងជនជាប់ចោទត្រូវបាន ផ្តល់នូវការដោះលែងឲ្យនៅក្រៅឃុំ។ ប៉ុន្តែ ក្នុងឆ្នាំ១៩៩៩ តុលាការ ICTY បានធ្វើ វិសោធនកម្មវិធាន៦៥ ស្តីពីការដោះលែងបណ្តោះអាសន្ន បានដកយកចេញមកវិញពីមេធាវីការពារក្តីនូវកាតព្វកិច្ចបង្ហាញភស្តុតាង "កាលៈទេសៈលើកលែងពិសេស" ។ "ហេតុផលនៅក្រោយវិសោធនកម្មនេះ គឺដោយសារចង់ឲ្យតុលាការ ICTY មានលក្ខណៈស្របគ្នានឹងនិយាមសិទ្ធិមនុស្សអន្តរជាតិ"[27]។ ក្រោយមកតុលាការ ICTR បានធ្វើវិសោធនកម្មវិធានពាក់ព័ន្ធរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ពាក្យពេចន៍អោយដូចគ្នានឹងតុលាការ ICTY[28]។

១៨. ក្នុងសេចក្តីសម្រេចលើករណី *Kallon* របស់តុលាការ SCSL តុលាការបានពិចារណាថា មេធាវីការពារក្តីជាអ្នកមានភារកិច្ច បង្ហាញថាការឃុំខ្លួនជនជាប់ចោទបន្ថែមទៀតគឺលែងមាន

---

[26] តុលាការ ICTY វិធាននីតិវិធីនិងភស្តុតាង សំណុំរឿងលេខ IT/32/Rev.38 ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ វិធាន៦៤។ សូមមើលផងដែរ វិធាននីតិវិធីនិងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ធ្វើវិសោធនកម្មកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ វិធាន៦៤។

[27] សេចក្តីសម្រេចករណី *Sessay* វាក្យខណ្ឌ២៥ ។

[28] តុលាការ ICTR, បទដ្ឋាននីតិវិធី និងភស្តុតាង, អនុម័តនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៥, វិសោធនកម្មនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ ។

ហេតុផលសមស្របទៀតហើយ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលមេធាវីការពារក្តីបញ្ជូនភស្តុតាងដើម្បីបំពេញទៅតាមលក្ខណៈវិនិច្ឆ័យស្តីពីការដោះលែងបណ្តោះអាសន្ន ដូចមានចែងក្នុងវិធាន RPE ៦៥ (ខ) អយ្យការត្រូវបានបង្ខំឲ្យផ្តល់ភស្តុតាង ដើម្បីទាត់ចោលអ្វីដែលបានដាក់ ហើយបង្ហាញថា សិទ្ធិរបស់ជនជាប់ចោទឲ្យមានការដោះលែង មិនអាចធៀបនឹងផលប្រយោជន៍របស់សាធារណជន ដែលទាមទារឲ្យមានការឃុំខ្លួនបន្តទៀតបានទេ[29]។

១៩. តុលាការ ICTY កត់សំគាល់ឃើញថា បន្ទុកដែលបានដាក់លើជនជាប់ចោទ គឺជាបញ្ហាដ៏សំខាន់បើប្រៀបធៀបទៅនឹងព្រំដែនយុត្តាធិការ និងការអនុវត្តរបស់តុលាការ។ បន្ទុកនេះគឺជាបន្ទុកធំដុំពីព្រោះតែព្រំដែនយុត្តាធិការរបស់តុលាការICTY។ កាលៈទេសៈទាំងនេះមិនអាចអនុវត្តនៅប្រទេសកម្ពុជាបានឡើយ ហើយ ក.ស.ច.ស មានកំហុសខុសឆ្គង ដែលបានផ្តោតជាសំខាន់ទៅលើបទដ្ឋានឃុំខ្លួនតាមអង្គហេតុនៃយុត្តិសាស្ត្ររបស់ខ្លួន[30]។

២០. ផ្ទុយទៅនឹងទឡ្ហីករណ៍របស់ក.ស.ព[31] ជំរើសដែលអាចយកមកប្រើប្រាស់សម្រាប់ការឃុំខ្លួនដើម្បីបំពេញលក្ខខណ្ឌវិធាន ៦៣(៣) ត្រូវតែបានពិចារណាដោយអនុគ្រោះ ជំនួសការឃុំខ្លួន។ ដូចបានចែងក្នុងវិធាន ៦៣(៣) សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបាន ល្គឹកណាទម្រង់ នៃការឃុំខ្លួនដែលពុំសូវតឹងរឹង មិនអាចឆ្លើយតបនឹងវត្ថុបំណងនៃ

---

[29] សេចក្តីសម្រេចករណី Sesay កថាខណ្ឌ ៣២-៣៣ ។

[30] *ព្រះរាជអាជ្ញា*តតាំងនឹង *Prlic* សំណុំរឿងលេខ IT-04-74- សេចក្តីសម្រេចស្តីពីការដោះលែង Slobodan Praljak ចុះថ្ងៃទី ៣០ កក្កដា ២០០៤ កថាខណ្ឌ ១៤ (សេចក្តីសម្រេចករណី Praljak) ។ អង្គជំនុំជម្រះសាលាដំបូងពិពណ៌នាថា "បន្ទុកបង្ហាញភស្តុតាងស្ថិតនៅលើជនជាប់ចោទដើម្បីធ្វើអោយអង្គជំនុំជម្រះសាលាដំបូងជឿរថា គាត់នឹងមានវត្តមានពេលជំនុំជម្រះ ហើយនិងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សី ឬបុគ្គលដទៃទៀតឡើយ។ បន្ទុករបស់ជនជាប់ចោទនេះគឺមានសារៈសំខាន់ធំធេង ដោយសារព្រំដែននៃយុត្តាធិការ និងការអនុវត្តរបស់តុលាការនេះ" ។ សូមមើល *រដ្ឋអាជ្ញា តតាំងនឹង Radoslav Brdjanin និង Momir Talic*, សំណុំរឿងលេខ IT-99-36PT សេចក្តីសម្រេចលើពាក្យសុំការដោះលែងបណ្តោះអាសន្នរបស់ Radoslav Brdjanin ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០, កថាខណ្ឌ១៨។

[31] ករណី នួន ជា, ០០២/១៩-០៩-២០០៧ -អ.វ.ត.ក/ក.ស.ច.ស (អបជ១៣), ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការពន្យារការឃុំខ្លួនបណ្តោះអាសន្ន, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨, វាក្យខណ្ឌ១៨។

ការឃុំខ្លួនបាន។ បើទោះជា ក.ស.ច.ស បានកំណត់ថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាការចាំបាច់ពីដំបូងក៏ដោយ មួយឆ្នាំក្រោយមក ក.ស.ច.ស ត្រូវធ្វើការវិភាគថ្មីមួយទៀត ដើម្បីបង្ហាញថា អង្គហេតុសំខាន់ៗទាំងនោះ នៅតែជាអង្គហេតុថ្មី ហើយត្រឹមត្រូវសម្រាប់បន្តការឃុំខ្លួន។ យុត្តិសាស្ត្រស្ដីពីសិទ្ធិមនុស្សបានរកឃើញដូចគ្នាថា ហានិភ័យដែលនាំឱ្យមានការឃុំខ្លួនពីដំបូងបានកាត់បន្ថយ នៅពេលដែលពេលវេលាចេះតែកន្លងផុតទៅ[32]។ ដូច្នេះ ក.ស.ច.ស នៅតែមានបន្ទុកក្នុងការបង្ហាញថា ការដកហូតសិទ្ធិទទួលបានសេរីភាពពីលោក **អៀង សារី** គឺជាការងារចាំបាច់។ សេចក្ដីសន្និដ្ឋានផ្សេងៗទៀតនឹងធ្វើឱ្យខូចខាតដល់វត្ថុបំណងនៃវិធាន៦៣(៦)(ក) ដែលកំណត់ថា ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នត្រូវពិនិត្យមួយឆ្នាំម្ដង ហើយប្រកាន់យកគោលការណ៍សច្ចធារណ៍និរទោស និងការរំពឹងអំពីការប្រតិបត្តិសិទ្ធិសេរីភាព។

**គ. ការខកខានមិនបានបន្ថែមភស្តុតាងនៅក្នុងសំណុំរឿង គឺមិនបានធ្វើឱ្យអ្នកអង្កេតសមហេតុផលម្នាក់ជឿថា កំរិតនៃភស្តុតាងដូចដែលបានចែងដោយវិធាន ៦៣(៣)(ក) ត្រូវបានបំពេញឡើយ**

២១. នៅក្នុងការវិភាគរបស់ខ្លួនថាតើមាន "មូលហេតុសមស្រប" ក្នុងការជឿថា លោក **អៀង សារី** អាចបានប្រព្រឹត្តឧក្រិដ្ឋកម្មឬអត់នោះ ក.ស.ច.ស ពឹងផ្អែកទាំងស្រុងទៅលើសេចក្ដីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដែលបានពិចារណាភស្តុតាងសំណុំរឿងប្រមូលបានត្រឹមកាល

[32] Garycki តទល់នឹង Poland របស់តុលាការ ECHR, ៣៨។ អ្នកដាក់ពាក្យបានគូសបញ្ជាក់ថា មិនបានផ្ដល់នូវហេតុផលពាក់ព័ន្ធគ្រប់គ្រាន់សម្រាប់ការពន្យារឃុំខ្លួនគាត់ឡើយ។ គាត់បានអះអាងថា ភាពទំនងនៃការកាត់ទោសធ្ងន់ ដែលគេនឹងដាក់មកលើគាត់ មិនអាចគ្រប់គ្រាន់ដើម្បីធ្វើយុត្តិកម្មនូវអំឡុងពេលទាំងស្រុងនៃការឃុំខ្លួនគាត់ឡើយ។ ទាក់ទងនឹងហានិភ័យនៃសម្ពាធដែលមានលក្ខណៈបង្ខិតបង្ខំទៅលើ P.S. (សហចុងចោទ) អ្នកដាក់ពាក្យអះអាងបន្ថែមថា ជាមួយនឹងការវិវឌ្ឍនៃការជំនុំជម្រះ ហានិភ័យបែបហ្នឹងជាបណ្ដើរៗលែងមានការទាក់ទងទៀតហើយ។ បន្ថែមលើនេះទៀត អាជ្ញាធរគួរបានពិចារណាអំពីការធានាផ្សេងៗទៀត ដើម្បីធានាថា គាត់នឹងត្រូវបង្ហាញខ្លួននៅសវនាការ ឧទាហរណ៍ ការដោះលែងឱ្យនៅក្រៅឃុំ ឬ ក្រោមការគ្រប់គ្រងរបស់នគរបាល។ ជាចុងក្រោយ អាជ្ញាធរមិនបានបង្ហាញនូវការយកចិត្តទុកដាក់ពិសេសណាមួយក្នុងដំណើរការនីតិវិធីឡើយ ។

បរិច្ឆេទនៃសវនាការក្នុងខែកក្កដា ឆ្នាំ២០០៨[33]។ ក.ស.ច.ស មិនបានរកឃើញភស្តុតាងថ្មីណាមួយប្រមូលបានចាប់តាំងពីកាលបរិច្ឆេទនេះឡើយ។ ក.ស.ច.ស គ្រាន់តែពឹងផ្អែកទាំងស្រុងទៅលើបទសម្ភាសន៍ថ្មីមួយជាមួយនឹងលោកស្រី Laurence Picq ដែលមិនបានទាំងលើកឡើងនូវការចោទប្រកាន់ថ្មីណាមួយឡើយ ហើយគ្រាន់តែនិយាយឡើងវិញនូវការចោទប្រកាន់ដែលមានស្រាប់ក្នុងសៀវភៅលោកស្រីប៉ុណ្ណោះ គឺសៀវភៅដែលបានដាក់ជូនដោយក.ស.ព ធ្វើជាផ្នែកមួយនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ[34]។

២២. ដូចនេះ ក.ស.ច.ស គឺគ្រាន់តែត្រូវវិលត្រឡប់ទៅប្រើប្រាស់ភស្តុតាង ដែលអង្គបុរេជំនុំជម្រះ បានយកជាសំអាងរួចមកហើយនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនរបស់ខ្លួន ។ ទោះបីជាភស្តុតាងនេះអាចត្រូវបានពិចារណាថាមានលក្ខណៈគ្រប់គ្រាន់ នៅពេលដែលដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នដើមត្រូវបានចេញក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ក៏ដោយ ការបង្ហាញភស្តុតាងច្បាស់លាស់ជាងនេះគឺជាការចាំបាច់ បន្ទាប់ពីការឃុំខ្លួនអស់រយៈពេលមួយឆ្នាំកន្លងមក ក្នុងអំឡុងនៃការស៊ើបសួរ[35]។ ដោយខកខានមិនបានកំណត់ភស្តុតាងថ្មីណាមួយទាក់ទងនឹងថាតើ លោក **អៀង សារី** អាចបានប្រព្រឹត្តឧក្រិដ្ឋកម្មដែល ខ្លួនកំពុងត្រូវបានចោទ ដើម្បីបំពេញបន្ថែមទៅលើភស្តុតាង ដែលបានកំណត់រួចហើយដោយអង្គបុរេជំនុំជម្រះនោះ ក.ស.ច.ស មិនបានបំពេញភារកិច្ចរកភស្តុតាងដាក់បន្ទុក ដើម្បីបង្ហាញថា លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) ត្រូវបានបំពេញនោះទេ។

---

[33] រឿងក្តីលោក **អៀង សារី**, ០០២/១៩-០៩-២០០៧ -អវតក/កសចស (អបជ០៣), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ **អៀង សារី**, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន")។ សវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងនៅថ្ងៃទី៣០ ខែមិថុនា និង ថ្ងៃទី១-៣ ខែកក្កដា ឆ្នាំ២០០៨ ។

[34] ដីកាបង្គាប់ឲ្យឃុំខ្លួនបន្ត, វាក្យខណ្ឌ១៣ ។ ក.ស.ច.ស ទទួលស្គាល់យ៉ាងជាក់ច្បាស់ថា ភស្តុតាងប្រមូលបានក្នុងអំឡុងបទសម្ភាសន៍ជាមួយលោកស្រី Laurence Picq មិនបានបង្កើតចេញជាភស្តុតាងថ្មី ប៉ុន្តែ "គ្រាន់តែបញ្ជាក់បន្ថែម និងបរិយាយការចោទប្រកាន់របស់លោកស្រី" ច្រើនជាង ។

[35] រឿងក្តី *Letellier តទល់នឹង ប្រទេសបារាំង* តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ១២៣៦៩/៨៦ ចុះថ្ងៃទី ២៦ មិថុនា ១៩៩១ កថាខណ្ឌ ៣៥។

## ឃ. វិធាន ៦៣(៣)(ខ) - ការបន្តដាក់ក្នុងមន្ទីរឃុំឃាំងគឺជាការមិនចាំបាច់

### ក. ការដាក់ក្នុងមន្ទីរឃុំឃាំងគឺមិនមែនជាទម្រង់តែមួយគត់នៃការឃុំខ្លួន ដែលបានអនុញ្ញាតដោយវិធានច្បាប់ឡើយ

២៣. ដីកាសម្រេចអំពីការបន្តការឃុំខ្លួន គឺពឹងផ្អែកទៅលើសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួន ដែលបានផ្ដល់ហេតុផលថា វិធានផ្ទៃក្នុង ("វិធាន") មិនមានចែងអំពីទម្រង់ដែលអាចយកមកប្រើប្រាស់ ជំនួសនៃការឃុំខ្លួនឡើយ និងបានចាត់ទុកសំណើរបស់មេធាវីការពារក្ដីឱ្យឃុំខ្លួនក្នុងផ្ទះថាជាសំណើឱ្យមានការដោះលែង ដោយមានលក្ខខណ្ឌទៅវិញ[36]។

២៤. អត្ថន័យនៃការឃុំខ្លួនមិនមានចែងក្នុងអត្ថបទគតិយុត្តិណាមួយនៃ អ.វ.ត.ក ឡើយ។ ក្នុងការវាយតម្លៃអំពីទស្សនាទាននៃការឃុំខ្លួន អ្នកសិក្សាស្រាវជ្រាវបានពិចារណាថា វា "គឺជាវិធានការមួយ ដែលត្រូវអនុវត្តដោយអាជ្ញាធរសាធារណៈ ដែលបង្ខាំងមនុស្សទុកក្នុងកន្លែងមួយ ប្រឆាំងនឹងឆន្ទៈរបស់ជននោះអស់មួយរយៈកាល និងក្នុងទីតាំងដែលមានព្រំដែន និងត្រូវបានរារាំងដោយកងកម្លាំង ឬដោយការគំរាមកំហែងនៃការប្រើប្រាស់កម្លាំង ដើម្បីកុំឱ្យចេញពីទីកន្លែងនោះ"[37]។ ទោះជាយ៉ាងណាក៏ដោយ គ្រាន់តែរឹតត្បិតទាំងការបម្លាស់ទីមិនត្រូវបានទុកថាជាការដកហូតសេរីភាពឡើយ។ ភាពខុសគ្នាគឺ "ស្ថិតនៅលើកម្រិត មិនមែនលក្ខណៈ នៃការកំហិតការបម្លាស់ទីនោះទេ"[38]។ ដូច្នេះការដកហូតសេរីភាពមិនមែនកំណត់ត្រឹមតែការការគិតគូរតែអំពីទំហំនៃការបម្លាស់ទីជាម៉ែត្រការនោះទេ។ ជាទូទៅ ការឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងត្រូវបានចាត់ទុកថាជាការដកហូតសិទ្ធិសេរីភាពរួចទៅហើយ។

---

[36] ដីកាបង្គាប់ឱ្យឃុំខ្លួនបន្ត, វាក្យខណ្ឌ ៣៣ ។

[37] Stefan Trechsel, សិទ្ធិមនុស្សក្នុងដំណើរការក្ដីព្រហ្មទណ្ឌ (Oxford: ឆ្នាំ២០០៥), ទំព័រ ៤១២ ។

[38] Ashingdane តតាំងនឹង ចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្ដឹងលេខ ៨២២៥/៧៨ ចុះថ្ងៃទី ២៨ ឧសភា ១៩៨៥ កថាខណ្ឌ៤១ ។ Engel និង អ្នកដទៃទៀត តតាំងនឹង ប្រទេសហូឡង់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្ដឹងលេខ ៥១០០/៧១ ៥១០១/៧១ ៥១០២/៧១ ៥៣៧០/៧២ ចុះថ្ងៃទី ៨ មិថុនា ១៩៧៦ កថាខណ្ឌ ៥៨ ។

២៥. អត្ថន័យដូចគ្នានេះអនុវត្តចំពោះការឃុំខ្លួនក្នុងផ្ទះ[39] សម្រាប់មនុស្សដែលត្រូវបានឃុំខ្លួនរង់ចាំការជំនុំជម្រះ ទោះក្នុងមន្ទីរពេទ្យក្តី[40] និងមណ្ឌលឃុំខ្លួនដូចគ្នានេះក្តី បើទោះជាបុគ្គលនោះអាចបម្លាស់ទីដោយសេរី ក្នុងទីតាំងទាំងនេះក៏ដោយ[41]។ តាមពិត ការឃុំខ្លួនក្នុងផ្ទះត្រូវបានពណ៌នាបន្ថែមទៀតដោយតុលាការ ICTY ថា "មានលក្ខណៈស្រាលជាងការដាក់គុក [ក្នុង] ខណៈដែលវាមានលក្ខណៈធ្ងន់ធ្ងរជាងការដោះលែងបណ្តោះអាសន្ន [...] ការឃុំខ្លួនក្នុងផ្ទះជាទម្រង់មួយនៃការឃុំខ្លួនដែរ"[42]។ ក្នុងករណីប្រឆាំងនឹង Sam Hinga *Norman* នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន[43] លោកចៅក្រម Justice Robertson បានធ្វើការវែកញែករវាងការឃុំខ្លួនក្នុងផ្ទះដែលតម្រូវឱ្យមានអ្នកយាម២៤ម៉ោងមកពីអាជ្ញាធរឃុំឃាំង ទោះបីជាស្ថិតក្នុងបរិយាកាសប្រកបដោយផាសុកភាពព័ទ្ធជុំវិញដោយផ្ទះឯកជនមួយជាជាងក្នុងបន្ទប់មន្ទីរឃុំឃាំងក៏ដោយ ក៏ការឃុំខ្លួនក្នុងផ្ទះដែលទាមទារឱ្យមានទីស្នាក់នៅក្នុងផ្ទះឯកជន នៅក្រៅការគ្រប់គ្រងរបស់អាជ្ញាធរ

---

[39] រឿងក្តី Vachev តតាំងនឹងប្រទេសប៊ុលហ្គារី តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ៤២៩៨៧/៩៨ ចុះថ្ងៃទី ៨ កក្កដា ២០០៤ កថាខណ្ឌ ៦៤ ។ រឿងក្តី CN តតាំងនឹងប្រទេសអ៊ីតាលី (លេខ១) តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ២៤៩៥២/៩៤ ចុះថ្ងៃទី ១១ មករា ២០០១ កថាខណ្ឌ៣៣ ។ រឿងក្តី Vittorio និង Luigi Mancini តតាំងនឹងប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ៤៤៩៥៥/៩៨ ចុះថ្ងៃទី ២ សីហា ២០០១ កថាខណ្ឌ១៧ ។ រឿងក្តី Lavents តតាំងនឹង ប្រទេស Latvia តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ៥៨៤៤២/00 ចុះថ្ងៃទី ២៨ វិច្ឆិកា ២០០២ កថាខណ្ឌ ៦៣ (ភាសាដើមជាបារាំង)។

[40] ECHR, Lavents តតាំងនឹង Latvia , កថាខណ្ឌ ៦៣ ។

[41] បើទោះជា តុលាការសិទ្ធិមនុស្សមិនតែងតែឯកភាពជាមួយនឹងយុត្តិសាស្ត្ររបស់ខ្លួនក៏ដោយ ទោះជាករណីដាច់ដោយឡែកពីគ្នាក៏ដោយ ក៏តុលាការនេះបានរកឃើញថា ការចាប់ខ្លួនប្រភេទក្នុងផ្ទះ គឺជាទម្រង់មួយនៃការឃុំខ្លួន។ សូមមើល រឿងក្តី Guzzardi តតាំងជាមួយនឹង ប្រទេសអ៊ីតាលី តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ៧៣៦៧/៧៦ ចុះថ្ងៃទី ៦ វិច្ឆិកា ១៩៨០ ដែលលក្ខខណ្ឌនៃការបញ្ជូនខ្លួនគាត់ត្រូវបានដាក់កម្រិតតែនៅក្នុងជំរំមួយស្ថិតនៅលើកោះដ៏តូចមួយនៅឆ្នេរ Sardinia។

[42] *ព្រះរាជអាជ្ញា*តតាំងនឹង Tihomir Blaskic, IT-95-14-T, សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវី ការពារក្តី ដែលបានដាក់អនុលោមទៅតាមវិធាន៦៤នៃបទដ្ឋាននីតិវិធី និងភស្តុតាង, ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៩៦, កថាខណ្ឌ១៣ ("សេចក្តីសម្រេចលើករណី Blaskic", ការគូសបញ្ជាក់ត្រូវបានបន្ថែម)។

[43] *ព្រះរាជអាជ្ញា*តតាំងនឹង *Sam Hinga Norman*, SCSL-2003-08-PT, សេចក្តីសម្រេចលើបណ្តឹងសម្រាប់ ការកែសម្រួលលក្ខខណ្ឌនៃការឃុំខ្លួន, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣, កថាខណ្ឌ៤ ។

ឃុំឃាំង ដែលដូចគ្នានឹងការឃុំខ្លួនដែលបានអនុវត្តចំពោះលោក Pinochet នៅចក្រភពអង់គ្លេសដែរ។ លោក Justice Robertson បានពិចារណាថា ទម្រង់ទីពីរនៃការឃុំខ្លួនក្នុងផ្ទះជាទម្រង់នៃការដោះលែងបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌមួយចំនួនត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាជាងទម្រង់មួយនៃការឃុំខ្លួន។ នៅក្នុងការវិភាគរបស់ពួកគេ អំណាចក្នុងការប្រតិបត្តិវិធីសាស្ត្រនៃការត្រួតពិនិត្យជាការងារសំខាន់ ដើម្បីចាត់ទុកថាជា "ការឃុំខ្លួន"។

២៦. វិធាន៦៣(៨)អនុញ្ញាតយ៉ាងពិសេសឱ្យ ក.ស.ច.ស ពិនិត្យឡើងវិញ នូវដីកាបង្គាប់ឱ្យឃុំខ្លួន។ វិធាននេះត្រូវបានពង្រាងឡើងដើម្បីផ្សាភ្ជាប់ទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងដើម្បីធានាថាការឃុំខ្លួនជនត្រូវចោទគឺមិនមែនមានលក្ខណៈរឹតត្បិតទេ តែជាការចាំបាច់ ដោយបានបញ្ជាឱ្យមានការពិចារណាឡើងវិញពីការគ្រប់គ្រង និងលក្ខខណ្ឌក្នុងការឃុំខ្លួនរៀងរាល់បួនខែម្តង ហើយ "ប្រសិនជាតម្រូវឱ្យមានសកម្មភាពអ្វីមួយនោះ សហចៅក្រមស៊ើបអង្កេតអាចចេញនូវដីកាដ៏សមស្រប"។ ការរៀបចំការឃុំខ្លួនរបស់ លោក **អៀង សារី** និងជនត្រូវចោទផ្សេងៗទៀតគឺតម្រូវឱ្យមានការកែសម្រួលមួយចំនួនហើយកន្លងមកនេះ ដោយបង្ហាញថា ទម្រង់ដែលអាចយកមកប្រើប្រាស់ជំនួសការឃុំខ្លួន ពិតជាមានចែងក្នុងវិធានផ្ទៃក្នុង[44]។ តាមពិត ជនត្រូវចោទមួយចំនួនត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ដែលស្ថិតក្រោមរូបភាពនៃការឃុំខ្លួនដើម្បីទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ[45]។

---

[44] សូមមើល*រឿងក្តីលោក* ***អៀង សារី,*** ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស, ដីកាឱ្យនាំខ្លួនជនត្រូវចោទពិនិត្យសុខភាព, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ និង ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ កសចស, ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស, ដីកាពាក់ព័ន្ធនឹងលក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្ន, ជូនដំណឹងដល់មេធាវីការពារក្តីនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ។ *រឿងក្តីលោក* ***អៀង សារី,*** ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស, A134, សំណើវេជ្ជបណ្ឌិតសុំឱ្យនាំខ្លួនលោក **អៀង សារី**មកមន្ទីរពេទ្យកាល់ម៉ែតដើម្បីពិនិត្យសុខភាព, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ។ និង A142, សំណើវេជ្ជបណ្ឌិតសុំឱ្យនាំខ្លួនលោក **អៀង សារី**មកមន្ទីរពេទ្យកាល់ម៉ែត ដើម្បីពិនិត្យសុខភាព, ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ។

[45] កាលៈទេសៈទាំងនេះត្រូវបានពិភាក្សានៅក្នុង ព្រះរាជអាជ្ញាតតាំងនឹង *Sam Hinga Norman,* តុលាការពិសេស SCSL-2003-08-PT, សេចក្តីសម្រេចលើបណ្តឹងឱ្យកែសម្រួលលក្ខខណ្ឌឃុំខ្លួន, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣, វាក្យខណ្ឌ៧, "អ្នកទោសស្ថិតនៅក្នុងមន្ទីរឃុំឃាំងដដែល ...។ល។ នៅពេលត្រូវបានបញ្ជូនទៅកាន់ទីតាំងផ្សេងទៀត មុននឹងចូលក្នុងសវនាការ

២៧. ក.ស.ច.ស ក៏បានទទួលស្គាល់ផងដែរថា អាចមានការបញ្ជាឲ្យមានការឃុំខ្លួន ប្រសិនបើវាជាការចាំបាច់ ដើម្បីបំពេញទៅតាមលក្ខខណ្ឌនានា ដែលមានចែងក្នុងវិធាន៦៣(៣)(ខ) ហើយដូច្នេះ ប្រសិនបើវត្ថុបំណងទាំងនេះអាចត្រូវសម្រេចបានដោយវិធីផ្សេងមួយទៀត វត្ថុបំណងទាំងនេះត្រូវតែពិចារណា[46]។ ដូច្នេះ ក.ស.ច.ស ត្រូវបានអនុញ្ញាតឲ្យធ្វើការកែសម្រួល ផ្សេងៗចំពោះលក្ខខណ្ឌឃុំខ្លួន ក្នុងនោះរួមទាំងការចេញដីកាឲ្យមានការឃុំខ្លួនក្នុងផ្ទះផងដែរ "ក្នុងករណីចាំបាច់"។ បទប្បញ្ញត្តិនេះគឺដូចគ្នានឹងវិធានដែលពាក់ព័ន្ធនឹងការឃុំខ្លួន ដែលបានអនុវត្តនៅតុលាការ ICTY[47], តុលាការ ICTR និង តុលាការពិសេស SCSL[48] ក្នុងការបង្គាប់អំពីលក្ខខណ្ឌនៃការឃុំខ្លួនក្នុងផ្ទះ។ ដូច្នេះ ការឃុំខ្លួនក្នុងផ្ទះគឺមិនមែនជាទម្រង់ដែលអាចយកមកប្រើប្រាស់ជំនួសតែមួយគត់នៃការឃុំខ្លួន ដូចមានចែងក្នុងវិធានផ្ទៃក្នុងតុលាការទាំងនេះឡើយ ប៉ុន្តែអំណាចក្នុងការផ្លាស់ប្តូរលក្ខខណ្ឌឃុំខ្លួនរបស់លោក **អៀង សារី** ពីការឃុំខ្លួននៅអង្គភាពឃុំឃាំង អ.វ.ត.ក ទៅជាការឃុំខ្លួនក្នុងផ្ទះ គឺជាជម្រើសដែល ក.ស.ច.ស និង អង្គបុរេជំនុំជម្រះអាចធ្វើបានយ៉ាងជាក់ច្បាស់។

**ខ. មានលក្ខខណ្ឌសមស្របមួយចំនួននៃការឃុំខ្លួនក្នុងផ្ទះ ដែលនឹងការពារដល់វត្ថុបំណងនៃវិធាន៦៣(៣)(ខ)**

២៨. ក.ស.ច.សអះអាងថា "គ្មានលក្ខខណ្ឌ*សមស្រប* [បញ្ជាក់ក្នុងច្បាប់ដើម] ណាមួយក្នុងការឃុំខ្លួនក្នុងផ្ទះ នឹងអាចត្រូវបានដាក់ចេញ ដែលអាចធានានូវវត្ថុបំណងនៃវិធាន៦៣(៣)(ខ) (iii-v) អោយបានដូចគ្នានឹងការឃុំខ្លួនបណ្តោះអាសន្នឡើយ"[49]។

---

ឬ នៅក្រៅគុកដើម្បីទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ (បើទោះជាត្រូវបានស្នាក់នៅ រយៈពេលវែងនៅក្នុងមន្ទីរពេទ្យក្តី) និងក្នុងបន្ទប់សវនាការ ខណៈក្នុងពេលជំនុំជម្រះ"។

[46] ដីកាបង្គាប់ឲ្យឃុំខ្លួនបន្ត, កថាខណ្ឌ ៣៨ ។

[47] បទដ្ឋាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, IT/32/Rev.38, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦, វិធាន៦៤ ។

[48] បទដ្ឋាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេស SCSL, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦, វិធាន៦៤ ។

[49] ដីកាបង្គាប់ឲ្យឃុំខ្លួនបន្ត, កថាខណ្ឌ ៣៦ ។

២៩. ការសង្កត់ធ្ងន់លើលក្ខខណ្ឌ *"សមស្រប"* ចង្អុលបង្ហាញថា ក.ស.ច.ស ទទួលស្គាល់ថា មានជម្រើសដែលអាចយកមកប្រើប្រាស់បានជំនួសការដាក់ក្នុងមន្ទីរឃុំឃាំង ដែលនឹងអាចឆ្លើយតបទៅនឹងវត្ថុបំណងនៃវិធាន៦៣(៣) ដែលចៅក្រមមិនទាន់បានបង្ហាប់កន្លងមក ដ្បិតពួកគេពិចារណាថាជម្រើសទាំងនេះមិនសមស្រប។ បើទោះជាអង្គបុរេជំនុំជម្រះសម្រេចថា ក.ស.ច.ស មានកាតព្វកិច្ចផ្តល់ហេតុផលចំពោះសេចក្តីសម្រេចរបស់ខ្លួនក៏ដោយ[50] ជាក់ស្តែងណាស់ដែលថា ដីកាសម្រេចឲ្យឃុំខ្លួនបន្តខកខានមិនបានរាប់បញ្ចូលលក្ខខណ្ឌណាមួយ ដែលអាចត្រូវបានភ្ជាប់នឹងការឃុំខ្លួនក្នុងផ្ទះឡើយ ប៉ុន្តែត្រូវបានបដិសេធ ដោយសារគ្មានហេតុផលសមស្រប។ ក.ស.ច.ស ក៏មិនបានពន្យល់អំពីហេតុផលណាមួយ ដែលជម្រុញឲ្យខ្លួនឈានដល់សេចក្តីសន្និដ្ឋាននេះឡើយ។ ត្រូវផ្តល់ហេតុផលផ្សេងៗ ដើម្បីចៀសវាងការសន្និដ្ឋានដែលថា សេចក្តីសម្រេចត្រូវបានធ្វើឡើងតាមតែអំពើចិត្ត និងដើម្បីការពារដ៏ត្រឹមត្រូវនូវសិទ្ធិរបស់ភាគីរងគ្រោះ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។

៣០. ក្នុងករណី *Blaskic* តុលាការ ICTY កត់សម្គាល់ឃើញថា នៅក្នុងយុត្តាធិការជាតិ លក្ខខណ្ឌនៃការឃុំខ្លួនក្នុងផ្ទះខុសគ្នាយ៉ាងខ្លាំង ពិសេសដោយវាផ្អែកទៅលើកាលៈទេសៈដាច់ដោយឡែកក្នុងករណីនីមួយៗ។ កិច្ចព្រមព្រៀងដ៏ទូលំទូលាយគឺថា វាត្រូវបានបង្កើតឡើងដើម្បីគ្របដណ្តប់លើការឃុំខ្លួនក្នុងផ្ទះផ្ទាល់ខ្លួនរបស់បុគ្គលនោះតែម្តង។ វាបានបញ្ជាក់យ៉ាងទូលំទូលាយក្នុងឧទាហរណ៍នៃច្បាប់ជាតិ និងអះអាងដោយតុលាការថា ការឃុំខ្លួននៅក្នុងផ្ទះគឺជាទម្រង់មួយនៃការឃុំខ្លួន។ តុលាការនេះក៏បានកត់សម្គាល់ដែរថា ច្បាប់ជាតិក៏បានចែងយ៉ាងជាក់លាក់ដែរអំពីការឃុំខ្លួនក្នុងផ្ទះ "នៅពេលជនជាប់ចោទមានជំងឺផ្លូវកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរនោះ [ឬ] នៅពេលជនជាប់ចោទគឺមនុស្សចាស់ជរា"[51]។

៣១. ខណៈដែលលក្ខខណ្ឌនៃការឃុំខ្លួនក្នុងផ្ទះខុសប្លែកគ្នាដូច្នេះ លក្ខណៈពិសេសរួមសម្រាប់ គ្រប់ប្រភេទទាំងអស់នៃការឃុំខ្លួនក្នុងផ្ទះ គឺសិទ្ធិរបស់អ្នកជាប់ឃុំឃាំងក្នុងការរួមរស់ជាមួយក្រុម

---

[50] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួន, កថាខណ្ឌ ៦៤ ។

[51] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួន, វាក្យខណ្ឌ ១៩ ។

គ្រួសារ និងសិទ្ធិជួបមេធាវីរបស់គាត់នៅឯកន្លែងឃុំឃាំងគាត់[52]។ ក្នុងករណី*Blaskic* តុលាការបានទទួលស្គាល់លក្ខខណ្ឌថា រាល់ចំណាយដែលពាក់ព័ន្ធនឹងការកែសម្រួលទាំងនេះ នឹងជាបន្ទុករបស់ជនជាប់ចោទ ឬអ្នកជួសមុខឱ្យជនជាប់ចោទ[53]។ តុលាការទទួលស្គាល់ថា ប្រសិនបើ *Blaskic* ត្រូវបានតម្រូវឱ្យស្ថិតក្នុងការឃុំខ្លួនក្នុងផ្ទះក្រោមការតាមដានរបស់នគរបាល យ៉ាងជិតដល់នោះ គាត់មិនអាចទំនងនឹងរត់គេចខ្លួនបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ វត្តមានរបស់គាត់នៅលើទឹកដីហូឡង់ អាចបង្កឱ្យមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។ តុលាការបានកត់សម្គាល់ទៀតថា *Blaskic* មិនមានជំងឺ ឬមនុស្សចាស់ជរាទេ[54]។ ទោះជាយ៉ាងណាក្តី ត្បិតជាការពិត ដែលថាបុរេលក្ខខណ្ឌជាមូលដ្ឋានមួយចំនួនសម្រាប់ផ្តល់ការឃុំខ្លួនក្នុងផ្ទះ មានការខ្វះខាតក្តី តុលាការនៅតែវិនិច្ឆ័យថា *Blaskic* គួរទទួលបានការឃុំខ្លួនក្នុងផ្ទះ យោងទៅតាមវិធាននានា ដូចមានពណ៌នាខាងក្រោម ៖

- ជនជាប់ចោទគួរស្ថិតនៅក្រោមការឃុំខ្លួនក្នុងគេហដ្ឋានរបស់ខ្លួន។
- គាត់មិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីប្រទេស លុះណាតែត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច។
- គាត់ត្រូវបានផ្តល់សិទ្ធិឱ្យចាកចេញពីផ្ទះតែដើម្បីទៅជួបមេធាវី, ក្រុមគ្រួសារ និងមិត្តភក្តិ ប៉ុណ្ណោះ។ រាល់ការជួបទាំងអស់នឹងត្រូវធ្វើឡើងនៅក្នុងអង្គភាពឃុំឃាំង។
- គាត់មិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីទីកន្លែងឃុំខ្លួននៅពេលផ្សេងទៀតឡើយ។
- គាត់នឹងត្រូវធានាការបង់សាហ៊ុយរាល់ចំណាយទាំងអស់ ដែលកើតឡើងដោយលក្ខខណ្ឌ ពិសេសនៃការឃុំខ្លួនគាត់ ដូចជាមន្ត្រីសន្តិសុខ ដែលតម្រូវឱ្យយាមការពារគាត់។

---

[52] តម្រូវការដាក់លាក់នៃការឃុំខ្លួនក្នុងផ្ទះពាក់ព័ន្ធមួយក្នុងចំណោមចំនុចខាងក្រោម៖ ជនជាប់ចោទអាចត្រូវបាន អនុញ្ញាតឱ្យរស់នៅក្នុងលំនៅដ្ឋាន ជាមួយក្រុមគ្រួសារខ្លួន តែមិនអនុញ្ញាតឱ្យទទួល ឬជួបអ្នកណាផ្សេងក្រៅពីមេធាវី ឬ វេជ្ជបណ្ឌិតគាត់ឡើយ ។ ឬគាត់អាចត្រូវបានអនុញ្ញាតឱ្យចេញពីទីកន្លែងស្នាក់នៅគាត់នៅម៉ោងពេលជាក់លាក់ក្នុងមួយ ថ្ងៃៗ និងសម្រាប់រយៈពេលខ្លី ឱ្យចូលរួមក្នុងសកម្មភាពដែលបានព្រមព្រៀងពីមុន ដូចជាកិច្ចការទាក់ទងនឹងការងារ ។ ឬគាត់អាចចាកចេញពីទីកន្លែងស្នាក់នៅគាត់សម្រាប់រយៈពេលខ្លី ដែលបានរៀបចំពីមុនៗសម្រាប់គោលបំណងជាក់លាក់, ដោយផ្អែកលើមូលដ្ឋានថា គាត់គួររាយការណ៍ឱ្យនគរបាលមុន និងបន្ទាប់ពីចាកចេញពីគេហដ្ឋានគាត់ ។ សេចក្តីសម្រេចលើករណី *Blaskic* វាក្យខណ្ឌ២២ ។

[53] សេចក្តីរឿងក្តី *Blaskic* កថាខណ្ឌ២២ ។

[54] ដូចយោងខាងលើ កថាខណ្ឌ២១ ។

- គាត់មិនត្រូវមានទំនាក់ទំនងអ្វីទាំងអស់ជាមួយប្រព័ន្ធផ្សព្វផ្សាយ។
- គាត់ត្រូវឆ្លើយតបឲ្យបានឆាប់រហ័សទៅនឹងរាល់ដីកា ដែលបង្គាប់ដោយតុលាការ។
- គាត់ត្រូវបញ្ជូនលិខិតឆ្លងដែន និងរាល់ឯកសារសំគាល់ខ្លួនទាំងអស់ឲ្យតុលាការ។
- គាត់មិនត្រូវទូរស័ព្ទ ឬទទួលទូរស័ព្ទអ្វីទាំងអស់នៅកន្លែងឃុំខ្លួនគាត់។
- រាល់លិខិតឆ្លើយឆ្លងផ្ញើរចេញពី និងផ្ញើចូលមកជនជាប់ចោទត្រូវធ្វើឡើងតែជាមួយតុលាការប៉ុណ្ណោះ និងត្រូវបានចាត់ចែងយោងទៅតាមវិធាននៃការឃុំខ្លួន។
- គាត់មិនត្រូវជូនដំណឹងអំពីទីតាំងនៃការឃុំខ្លួនគាត់ទៅកាន់ជនណាម្នាក់ឡើយ។
- ប្រសិនបើមានការបំពានធ្ងន់ធ្ងរទៅលើវិធានទាំងនេះនឹងទទួលលទ្ធផលនៃការព្យួរឃ្លាមៗនូវការឃុំខ្លួនក្នុងផ្ទះ។ អាជ្ញាធរតុលាការដែលមានសមត្ថកិច្ចនឹងកំណត់ថាតើការបំពានធ្ងន់ធ្ងរណាមួយត្រូវបានប្រព្រឹត្ត និងថាតើតម្រូវឲ្យមានការបញ្ជូនខ្លួនគាត់ទៅកាន់អង្គភាព ឃុំឃាំង ឬអត់នោះ[55]។

៣២. ដូច្នេះ វាមានលក្ខខណ្ឌដែលអាចភ្ជាប់ទៅនឹងការឃុំខ្លួនក្នុងផ្ទះ ដែលធ្លាប់បានបង្គាប់ដោយតុលាការផ្សេងៗ។ តាមន័យនេះការបកស្រាយនានា លក្ខខណ្ឌទាំងអស់នេះត្រូវបានគេពិចារណាឃើញថាមានលក្ខណៈសមហេតុសមផល។ ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យលក្ខខណ្ឌ នានាខាងលើ និងធ្វើការផ្ទៀងផ្ទាត់ថា លក្ខខណ្ឌទាំងនោះសមហេតុសមផលឬទេមួយ យ៉ាងណា និងថាតើលក្ខខណ្ឌទាំងនោះអាចមានធាតុគ្រប់គ្រាន់ដើម្បីការពារគាំទ្រគោលបំណង ដូចដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) ឬមួយយ៉ាងណា។

**ខ. វិធាន ៦៣(៣)(ខ)- គោលបំណងទាំងអស់នៅក្នុងវិធាន ៦៣(៣)(ខ) ត្រូវបានគាំទ្រដោយលក្ខខណ្ឌនៃការឃុំខ្លួន**

---

55 សេចក្តីរឿងក្តី *Blaskic* កថាខណ្ឌ២៤, ២៥ ។

៣៣. ក.ស.ច.ស បានគូសបញ្ជាក់ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាការចាំបាច់ដើម្បីធានាចំពោះគោលបំណងទាំងបី ក្នុងចំណោមគោលបំណងផ្សេងទៀត៣នៃវិធាន ៦៣(៣)(ខ)[56]។ ការសន្និដ្ឋាននេះជាញឹកញាប់ មិនត្រូវបានផ្អែកទៅលើអ្វីទាំងអស់ក្រៅពីការអះអាងបញ្ជាក់ដែលមានលក្ខណៈជាការសន្មត ឬដែលផ្អែកលើអាចជាភ័ស្តុតាងដែលមិនពាក់ព័ន្ធ ឬកត្តាមិនចាំបាច់ ឬហួសសម័យកាល ឬកត្តាផ្សេងៗដែលវាហួសពី អ្វីដែលការត្រួតត្រាទាំងស្រុងរបស់លោក **អៀង សារី** អាចគ្រប់គ្រងបាន។

៣៤. លើសពីនេះទៅទៀត ការវិភាគរបស់ ក.ស.ច.ស ដែលបាននាំទៅរកការសន្និដ្ឋានបែបនេះ បណ្តាលមកពីត្រូវបានសម្លឹងទៅលើការខកខានរកឲ្យឃើញនូវភាពសមហេតុផលដ៏ប្រាកដនិយមជាសារវន្តមួយ[57]។ ការខកខាននេះត្រូវបានបង្កើតតាមរយៈការសំអាងហេតុជាជំហានដូចតទៅនេះ។ ទីមួយជាដំបូង ក.ស.ច.ស បាន បង្ហាញពីគោលបំណងនៅក្នុងវិធាន ៦៣(៣)(ខ) ដែលចាំបាច់ត្រូវតែការពារ។ ទី ២ ក.ស.ច.សបានអះអាងថា ការឃុំខ្លួនជាការសមស្របនឹងគោលបំណងទាំងនេះ។ ដូច្នេះ ជាផលវិបាក វិធាននេះ ក.ស.ច.ស នេះបានទាញហេតុផលបញ្ជាក់ហេតុផលថា ការឃុំខ្លួនគឺជា "ការចាំបាច់" ដើម្បីការពារគោលបំណងទាំងនេះ។ កំហុសដ៏ជាក់ច្បាស់នៅក្នុងការទាញបញ្ជាក់ហេតុផលនេះគឺថា ការសន្និដ្ឋាននេះមិនទាញចេញសមស្របជាមួយពីគំនិតសេចក្តីអះអាង ២ ដំបូងទេ។ បើនៅពេលដែលការឃុំខ្លួនអាចឆ្លើយតបបានតាមវាស្របជាមួយគោលបំណងនៃវិធាន ៦៣(៣)(ខ) ដូច្នេះលក្ខខណ្ឌដ៏សមស្របនៃការឃុំខ្លួននៅផ្ទះក៏អាចសមស្របជាមួយបំពេញបាននូវគោលបំណងទាំងនេះដែរ។ ដូចនេះ ការឃុំខ្លួនមិនមែនជាការចាំបាច់នោះទេ។

---

[56] ដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៣៦។

[57] *រឿងក្តីលោក* ***អៀង សារី*** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សារណាលោក **អៀង សារី** ប្រឆាំងនឹងការសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៨។

00250437

C22/5/I



***ក) វិធាន ៦៣(៣)(ខ)(i) ដើម្បីរារាំងកុំឲ្យជនត្រូវចោទធ្វើការគាបសង្កត់នៅលើសាក្សី និងជនរងគ្រោះ ឬត្រូវរួមឃុបឃិតរវាងជាមួយជនត្រូវចោទ និង (ii) ដើម្បីរារាំងមិនឲ្យមានការបំផ្លាញភ័ស្តុតាង***

៣៥. ក.ស.ច.ស បានទទួលយកការសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានកំណត់ថា នៅក្នុងករណីរបស់អៀង សារី ការឃុំខ្លួនបណ្តោះអាសន្នមិនមែនជាវិធានការ ដ៏ចាំបាច់ដើម្បីនោះទេក្នុង ការការពារសាក្សី រារាំងការត្រូវរួមគ្នាសមគំនិតគ្នា ឬថែរក្សា និងរារាំងមិនឲ្យបំផ្លាញភ័ស្តុតាង នោះទេ[58]។

***ខ) វិធាន ៦៣(៣)(ខ)(iii) ដើម្បីរារាំងហានិភ័យនៃការរត់គេចខ្លួនដោយ ជនត្រូវចោទ***

៣៦. គោលបំណងនេះសំដៅមានបំណងធានាឲ្យមានការចូលរួមរបស់ជនត្រូវចោទ នៅគ្រប់ដំណាក់កាលនៃនីតិវិធីសវនការ និងដើម្បីទទួលទោសសម្រាប់ការដាក់ទោសណាមួយដែលបានបង្គាប់នៅក្នុងករណី ដែលមានការកាត់ឲ្យជាប់ទោស។ នៅក្នុងការអះអាងថាលោក **អៀង សារី** អាចរត់គេចខ្លួន ក.ស.ច.ស បានគូសបញ្ជាក់នូវកត្តាផ្សេងៗដូចជា៖ (ក) ទំនាក់ទំនងរបស់ អៀង សារី ជាមួយមន្ត្រីនៅក្រុងប៉ៃលិន។ (ខ) លទ្ធភាពមានធនធានហិរញ្ញវត្ថុដើម្បីរត់គេចខ្លួន។ (គ) មានលិខិតឆ្លងដែន និងមានខ្សែរយៈនៅឯបរទេស និង (ឃ) មានការជំរុញគ្រឿងលើកទឹកចិត្តឲ្យរត់គេចខ្លួន នៅពេលដែលជននេះស្ថិតនៅក្រោមការស៊ើបអង្កេត[59]។

៣៧. ហានិភ័យដែលលើកឡើងដោយ ក.ស.ច.ស គឺជាហានិភ័យដោយការសន្មតតែប៉ុណ្ណោះ មិនមែនជាហានិភ័យពិតប្រាកដ ដែលផ្អែកលើមូលដ្ឋានភ័ស្តុតាងដ៏រឹងមាំណាមួយទេ។ នៅក្នុងករណី *Prlic នៅICTY* តុលាការ ICTY ក៏បានរកឃើញថាការជំទាស់របស់រដ្ឋអាជ្ញាទៅនឹងការដោះលែងបណ្តោះអាសន្នមិនមានមូលដ្ឋានភស្តុតាងគាំទ្រទេ ពោលគឺការជំទាស់នោះមិនមានភស្តុតាងគាំទ្រគ្រប់គ្រាន់ ដើម្បីបដិសេធចោលភស្តុតាងរបស់ជនជាប់ចោទដែលថា ខ្លួនគួរទទួលបានការដោះ

---

[58] សេចក្តីសម្រេចលើបណ្តឹង ឧទ្ធរណ៍ស្តីពីការឃុំខ្លួន កថាខណ្ឌ ១០០។

[59] ដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ២១។

លែងបណ្ដោះអាសន្ន ។ តុលាការICTY នេះបានសន្និដ្ឋានថា ខ្លួនមិនអាចរកឃើញសញ្ញាជាក់ច្បាស់រឹងមាំណាមួយចង្អុលបង្ហាញថា ជនជាប់ចោទបានព្យាយាមរត់គេចខ្លួននោះទេ[60]។

៣៨. ក.ស.ច.ស បានខកខានមិនបានធ្វើការពិចារណាដ៏សមស្របចំពោះការពិតដែលថា ទោះបីជាលោក **អៀង សារី** អាចមានឥទ្ធិពល និងធនធានដូចដែលបានចោទប្រកាន់មែនក្ដីដូចករណីលោក **អៀង សារី** និងនៅក្នុងកាលៈទេសៈដែលគាត់ពិតជាបានដឹងអំពីការស៊ើបអង្កេត ដែលអាចធ្វើប្រឆាំងនឹងរូបគាត់ក្ដីក៏ដោយ ក៏មិនមានភ័ស្តុតាងណាដែលបញ្ជាក់ថា គាត់បានត្រៀមរៀបចំអនុវត្តនូវសកម្មភាពក្នុងការរត់គេចខ្លួន ឬរំខានដល់ដំណើរការតុលាការការគ្រប់គ្រងយុត្តិធម៌នោះដែរ។ ប្រសិនបើលោក **អៀង សារី** ពិតជាមានបំណងចង់រត់គេចខ្លួនមែននោះ គាត់ប្រហែលប្រាកដជាធ្វើបែបនោះតាំងពីយូរមកហើយមុនហ្នឹងទៅទៀត។ ផ្ទុយទៅវិញ គាត់បានរង់ចាំយ៉ាងអត់ធ្មត់នៅក្នុងទីក្រុងភ្នំពេញដើម្បីជួយដល់ដំណើរការការគ្រប់គ្រងវិស័យយុត្តិធម៌នេះ[61]។ តាមពិតទោះបីជាមានការពិតដូចដែលបានចោទប្រកាន់ថាលោក **អៀង សារី** មានឥទ្ធិពល ប្រាក់កាស និងលិខិតឆ្លងដែនក៏ដោយក៏លោក **អៀង សារី** មិនមានបំណងសូម្បីបន្តិចណាសោះក្នុងការរំខានដល់ដំណើរការតុលាការការគ្រប់គ្រងយុត្តិធម៌នោះឡើយ[62]។ អាយុកាន់តែចាស់ជរាដ៏ទន់ជ្រេរបស់លោក **អៀង សារី** និងការពិតដែលថា ប្រពន្ធរបស់គាត់ក៏ស្ថិតនៅក្នុងការឃុំខ្លួនផងដែរនោះ បាន

---

[60] *ព្រះរាជអាជ្ញា ទល់នឹង Prlic,* IT-04-74-AR65.1; IT-04-74-AR65.2; IT-04-74-AR65.3 សេចក្ដីសម្រេចលើសារណាសុំឲ្យពិចារណាឡើងវិញ ការបំភ្លឺឡើងវិញ សំណើសុំដោះលែង និងពាក្យសុំអនុញ្ញាតិប្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ២៧ (សេចក្ដីសម្រេចករណី Prlic)។

[61] សេចក្ដីសម្រេចករណី Prlic កថាខណ្ឌ ៣០ អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY បានកត់សម្គាល់ថា ការពិតដែលថាជនជាប់ចោទមិនបានព្យាយាមរត់គេចខ្លួនមុនការចាប់ខ្លួនរបស់គាត់ ដែលបានគាំទ្រភាពដែលអាចដែលគាត់នឹងមកបង្ហាញខ្លួននៅក្នុងពេលសវនាការ នៅពេលដែលមានការបង្គាប់ដូច្នេះដោយអង្គជំនុំជម្រះសាលាដំបូង។ "នេះជាការពិតជាពិសេសពីព្រោះជនជាប់ចោទបានដឹងជាមុនថា គាត់អាចត្រូវបានចោទប្រកាន់ដោយសាលាក្ដី ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ស្របថាជនជាប់ចោទមិនបានព្យាយាមលាក់ខ្លួន ទោះបីបានទទួលសញ្ញាថា គាត់ជាជនសង្ស័យម្នាក់ដែលស្ថិតនៅក្នុងយុត្តាធិការរបស់សាលាក្ដី និងថា គាត់អាចប្រឈមការកាត់ទោសដ៏ធ្ងន់ធ្ងរ ប្រសិនបើប្រត្រូវបានកាត់ឲ្យជាប់ទោសមែននោះ"។

[62] សេចក្ដីសម្រេចករណី Prlic កថាខណ្ឌ ២៨។

បង្ហាញយ៉ាងច្បាស់ថា គាត់មិនមានទាំងលទ្ធភាព និងកម្លាំងទាំងការលើកទឹកចិត្តឲ្យធ្វើការរត់គេចខ្លួននោះក៏ទេដែរ[63]។

៣៩. ក.ស.ច.ស ក៏មានការភ័ន្តច្រឡំដោយខកខានមិនបានពិចារណាថាតើ វិធីសាស្ត្រដែលមិនសូវតឹងរ៉ឹងនៃការឃុំខ្លួន ឬការដោះលែងនេះអាចនឹងអាចឆ្លើយតបបាន ឬមិនបាន តាមបំពេញតាមគោលបំណងនេះ ឬមួយយ៉ាងណានោះទេ។ តាមពិត វាមានលក្ខខណ្ឌជាជម្រើសជាច្រើនក្នុងការជំនួសឲ្យការឃុំខ្លួន ឬដោះលែង មួយចំនួនដែល អាចបំពេញឲ្យគោលបំណងនេះ។វាលែងល្អីកណាតែ ក.ស.ច.ស កំណត់ឲ្យឃើញថា ពិតជាគ្មាន ទម្រង់ជំនួសឲ្យការឃុំខ្លួនណាមួយអាចដែលបំពេញនូវគោលបំណងនេះបាន នោះទើបការចេញដីកាឲ្យ ឃុំខ្លួនអាចធ្វើទៅបាន។

៤០. មេធាវីការពារក្តីសូមលើកឡើងថា លក្ខខណ្ឌដែលមានសម្រាប់ការឃុំខ្លួននៅក្នុងផ្ទះមាន ដូចជា៖ (១) ការបង្ខាំងខ្លួននៅក្នុងគេហដ្ឋានរបស់គាត់។ (២) ការដកហូតយកលិខិត ឆ្លងដែនរបស់គាត់ និង (៣) ការដាក់គាត់នៅក្នុងគេហដ្ឋានរបស់គាត់ដោយមានការយាមកាមពីកងកម្លាំងប្រដាប់អាវុធ ដែលលក្ខខណ្ឌទាំងនេះនឹងធានាឲ្យមានវត្តមានរបស់លោក **អៀង សារី** នៅក្នុងសវនការ។ វិធានការទាំងនេះមានលក្ខណៈសមហេតុផល ជាពិសេស ប្រសិនបើការចំណាយសម្រាប់ការយាមកាមបែបនេះ គឺជាបន្ទុកទាំងស្រុងរបស់លោក **អៀង សារី** ឬធ្វើឡើងក្នុងនាមរូបគាត់ **អៀង សារី** មែននោះ[64]។

៤១. គោលបំណងនៃវិធានផ្ទៃក្នុង ៦៣(៣)(ខ)(iv) គឺត្រូវការពារសន្តិសុខផ្ទាល់ខ្លួនបុគ្គលរបស់ជនត្រូវចោទ ពោលគឺទាំងធានាទាំងឲ្យគាត់មានវត្តមានរបស់គាត់នៅក្នុងពេលសវនាការ និងដើម្បីការពារ

---

[63] សេចក្តីសម្រេចអំពីបណ្តឹងឧទ្ធរណ៍នៃការឃុំខ្លួន កថាខណ្ឌ ២៨។

[64] លក្ខខណ្ឌជំនួសដែលកាត់បន្ថយ ឬលុបបំបាត់ហានិភ័យនៃការរត់គេចខ្លួនអាចត្រូវបានមើលឃើញនៅក្នុងលក្ខខណ្ឌនៃការដោះលែងបណ្តោះអាសន្នដែលអនុវត្តចំពោះ Jovica Stanisic ដូចបានរៀបរាប់នៅក្នុង *ព្រះរាជអាជ្ញា ទល់នឹង Jovica Stanisic* IT-03-69-PT សេចក្តីសម្រេចលើការដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៦៨។

សិទ្ធិជាមនុស្ស របស់គាត់[65]។ ក.ស.ច.ស បានពិចារណាឃើញថា នៅពេលណាដែល វាលេចឮជាសាធារណៈថា មានទំនាក់ទំនងដូចដែលបានចោទប្រកាន់រវាង **ឌុច** និងលោក **អៀង សារី** មែននោះ នោះការគម្រាមកំហែងចំពោះលោក **អៀង សារី** នឹងមានការកើនឡើង ហើយការឃុំខ្លួនក្នុងទម្រង់នៃការដាក់ឃុំឃាំងក្នុងពន្ធនាគារ គឺវាជាការចាំបាច់ដើម្បីរក្សាសន្តិសុខរបស់ជនត្រូវចោទ[66]។

៤២. ទឡ្ហីករណ៍នេះផ្អែកទាំងស្រុងលើការសន្មតជាមុនថាលោក **អៀង សារី** មានកំហុសពិរុទ្ធ ព្រោះដោយសារតែទឡ្ហីករណ៍នេះហាក់ដូចពិតជាបង្ហាញច្បាស់ថា (ក) មានទំនាក់ទំនងបែបនេះពិតប្រាកដមែន។ (ខ) ពិរុទ្ធភាពដូចដែលបានរងការចោទប្រកាន់របស់ **ឌុច** រងការចោទប្រកាន់ដូចគ្នាទៅនឹងជាទទួលរងពិរុទ្ធភាពរបស់ស្មើគ្នាដូចលោក **អៀង សារី** មែន។ វាពិតជាមិនមិនអាចទទួលយកបានទេចំពោះ ក.ស.ច.ស ក្នុងការគិតទុកជាមុននូវពិរុទ្ធភាពរបស់លោក **អៀង សារី** ហើយវារំលោភទៅលើគោលការណ៍សច្ចធារណ៍និរទោស។ ការរំលោភបែបនេះ ចោទជាសំណួរអំពីភាពលម្អៀងនៃការស៊ើបសួរទាំងមូលរបស់ ក.ស.ច.ស ។

៤៣. ទឡ្ហីករណ៍នេះក៏បានទទួលស្គាល់បន្ថែមទៀតថា ក.ស.ច.ស មិនបានរកពិចារណាឃើញច្បាស់ថាអំពីការពិតជាមានការគម្រាមកំហែងប្រឆាំងនឹងលើលោក **អៀង សារី** ដែលមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់តម្រូវឲ្យមាន ដែលតម្រូវឲ្យមានការឃុំខ្លួនបណ្តោះអាសន្ននោះទេ។ ពោលជាងនេះទៅទៀតគឺ មានតែនៅពេលដែលមានការចោទប្រកាន់អំពីអត្ថិភាពនៃការមានទំនាក់ទំនងរវាងអ្នក

---

[65] ទោះបីសញ្ញាណអំពីបញ្ហាសន្តិសុខមិនសូវច្បាស់ក្តី វាហាក់ដូចជាថា ការបកស្រាយដោយតុលាការសំដៅលើសុវត្ថិភាពរូបកាយពីការវាយប្រហារ។ ជាប្រវត្តិសាស្ត្រ ទស្សនាទាននេះត្រូវបានគេបកស្រាយថា ជាការការពារខ្លួនពីអ្នកដទៃ (STAFAN TRACHSEL សិទ្ធិមនុស្សនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ (Oxford: 2005) ទំព័រ ៤០៥-៤៥៤ ទំព័រ ៤០៩) ទោះបីជាយុត្តិសាស្ត្រតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ខ្លួន "ជាអ្នកធានាមិនមានមានការចាប់ខ្លួន និងឃុំខ្លួនតាមអំពើចិត្ត ក៏ដោយ" (*Arrowsmith ទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំ ៧០៥០/៧០ កថាខណ្ឌ ៦៤។ សូមអានផងដែរ *Winer ទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំ ១០៨៧១/៨៤)។ តុលាការសិទ្ធិមនុស្សអឺរ៉ុបក៏បានសម្រេចផងដែរថា ខ្លួនមិនអាចយល់ ត្រឹមអត្ថន័យនៃពាក្យការពារពីការវាយប្រហារដោយខុសច្បាប់ (*X ទល់នឹង ប្រទេសអាល្លឺម៉ង់* ពាក្យសុំ ៨៣៣៤/៧៨) និងបានបញ្ចប់ជាស្ថាពរនូវបញ្ហានៅក្នុង *Bozano ទល់នឹង* បារាំង កថាខណ្ឌ ៥៤ និង ៦០។

[66] ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ២៧។

ទាំងពីរមួយនេះ ដែលត្រូវបានដឹងជាសាធារណៈតែម្តងគត់ ដែលត្រូវបានដឹងជាសាធារណៈដែលចៅក្រមស៊ើបអង្កេតយល់ឃើញថាមាន បើដូច្នេះមែន តើការគម្រាមកំហែងនេះវានឹងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីក្នុងការដកហូតសិទ្ធិមានសេរីភាពរបស់លោក **អៀង សារី** បានដែរឬទេ។

៤៤. លុះណាការគម្រាមនេះគឺជាការពិត បើមិនដូច្នោះទេនោះ លក្ខខណ្ឌនេះនៃការគម្រាមកំហែងមិនអាចត្រូវបានប្រើប្រាស់ដើម្បីបន្តការឃុំខ្លួនបានទៀតទេ។ ដូច្នេះ ក.ស.ច.ស បានធ្វើខុសនឹងច្បាប់ដោយប្រើនូវគោលបំណងនេះដើម្បីបង្ហាញថា ការឃុំខ្លួនពិតជាការត្រឹមត្រូវទៅវិញ[67]។

៤៥. ទំនាក់ទំនងរវាងលោក **អៀង សារី** និង **ឌុច** បានក្លាយជាប្រធានបទនៃការអត្ថាធិប្បាយកេងយកកម្រៃរបស់ប្រព័ន្ធផ្សព្វផ្សាយរួចទៅហើយ ចំណែកសាធារណៈជនក៏បានជឿយ៉ាងទូលំទូលាយរួចទៅហើយថា មានការចោទប្រកាន់អំពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលបទល្មើសដែលបានអះអាងរបស់ឌុចរងការចោទប្រកាន់ មានទំនាក់ទំនងទៅនឹងការចោទប្រកាន់ផ្សេងៗប្រឆាំងលោកការចោទប្រកាន់ប្រឆាំងនឹងលោក **អៀង សារី**[68]។ ដូច្នេះ ប្រសិនបើទំនាក់ទំនងបែបនេះត្រូវ បានរកឃើញមែននោះ ការគម្រាមកំហែងចំពោះលោក **អៀង សារី** នឹងមិនកើតឡើងជាដុំកំភួននោះទេ ពីព្រោះសាធារណៈជនបានជឿយ៉ាងទូលំទូលាយរួចទៅហើយថា គាត់មានពិរុទ្ធពីនៃបទឧក្រិដ្ឋកម្មនានា។ ដូច្នេះ ជាការពិត ក.ស.ច.ស មានការភ័ន្តច្រឡំលើអង្គហេតុ ក្នុងការពិចារណាថា ការកើតឡើងនូវការគម្រាមកំហែងចំពោះលោក **អៀង សារី** នឹងបណ្តាលមកពីការរកឃើញពីទំនាក់ទំនងដែលគេចោទប្រកាន់នោះ។

៤៦. ជាថ្មីម្តងទៀត ក.ស.ច.ស អាក់ខានមិនបានពិចារណាម្តងទៀតថា តើអាចមានទម្រង់ជំនួសឲ្យការឃុំខ្លួន ឬដោះលែងណាមួយ ដែលអាចបានបំពេញតាមគោលបំណងនៃវិធាន ៦៣(៣)(ខ)(iv)បាន ឬយ៉ាងណានោះទេ ។ ក.ស.ច.ស ក៏បានកំណត់សម្រេចដែរថា មិនមានទម្រង់ជំនួសឲ្យការឃុំខ្លួន

---

[67] ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ២៨។

[68] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣) សេចក្តីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់អៀង សារី ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥។

ណាមួយដែលអាចបំពេញនូវគោលបំណងនេះបានទេនោះឡើយ ប្រសិនបើការដាក់ពន្ធនាគារត្រូវបានសម្រេចមែននោះ។

៤៧. មេធាវីការពារក្តីបានបញ្ជាក់រួចមកហើយថា វាមិនមានហានិភ័យដ៏ជាក់ស្តែងដែលគម្រាមកំហែងដល់សន្តិសុខផ្ទាល់ខ្លួនរបស់លោក **អៀង សារី** នោះទេ ហើយទម្រង់ជំនួសនានាដូចជា ការឃុំខ្លួននៅក្នុងផ្ទះជាដើម តាមពិតវាជួយបង្កើនសុវត្ថិភាពរបស់គាត់ ហេតុដូច្នេះ ការណ៍នេះវានឹងបំពេញតាមគោលបំណងក្នុងការធានាសន្តិសុខរបស់គាត់លើសពីអ្វីដែល បានផ្តល់ជូននាពេលបច្ចុប្បន្ននេះ តាមរយៈការដាក់ឲ្យជាប់ឃុំទៅទៀត[69]។ គេអាចផ្តល់នៅឯគេហដ្ឋានរបស់លោក **អៀង សារី** ដូចជាវត្តមានរបស់សន្តិសុខដើម្បីធានាថា លក្ខខណ្ឌនៃការឃុំខ្លួននៅក្នុងផ្ទះនឹងលុបបំបាត់រាល់ហានិភ័យដែលមិនអាចទទួលយកបានណាមួយចំពោះសន្តិសុខរបស់គាត់[70]។ ការផ្តល់បែបនោះ គឺវាស្ថិតនៅទាំងស្រុងក្នុងអំណាចរបស់តុលាការដែលបានផ្តល់ការគាំទ្រចំពោះការការពារខ្លួន និងសន្តិសុខដល់ចៅក្រមរបស់ អ.វ.ត.ក សមាជិកជាន់ខ្ពស់នៃការិយាល័យសហព្រះរាជអាជ្ញា និងសូម្បីប្រធានអតីតផ្នែកគាំពារការពារក្តី។ បុគ្គលិកជាច្រើនរបស់តុលាការ និងគ្រួសារខ្មែរក៏បានជួលសន្តិសុខឲ្យយាមគេហដ្ឋានរបស់ពួកគេជាប្រចាំផងដែរ។

**ឃ) វិធាន ៦៣(៣)(ខ)(v) ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ**

[69] ដូចយោងខាងលើ កថាខណ្ឌ ២៣ ដែលបានកត់សម្គាល់ ថា លក្ខខណ្ឌបន្តការឃុំខ្លួនធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ជនត្រូវចោទ។

[70] តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) បានពិចារណាសន្តិសុខនៃការឃុំខ្លួននៅក្នុងផ្ទះក្នុង *រដ្ឋអាជ្ញា ទល់នឹង Sam Hinga Norman* SCSL-2003-08-PT សេចក្តីសម្រេចលើសារណាសម្រាប់កែប្រែលក្ខខណ្ឌនៃការឃុំខ្លួន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ១២។ តុលាការបានពិចារណាថា កាលៈទេសៈនៃការឃុំខ្លួននៅក្នុងផ្ទះរបស់ Blaskic មិនត្រូវបានបំពេញ ហើយថាពួកគេត្រូវរកឲ្យឃើញនូវភាពដែលមិនអាចអនុវត្តបាននេះ។ ទោះយ៉ាងនេះក្តី តុលាការបានកត់សម្គាល់ថា សេចក្តីសម្រេចជាបន្តបន្ទាប់មួយដែលពាក់ព័ន្ធនឹងបញ្ហាសន្តិសុខបានដោះស្រាយបញ្ហាទាំងឡាយដោយដាក់ឲ្យគេយាមជនជាប់ចោទ នៅពេលដែលជននោះនៅឯផ្ទះ។

៥៨. គោលបំណងនៃវិធាន ៦៣(៣)(ខ)(v) គឺដើម្បីរាំងនូវហានិភ័យដ៏ជាក់ស្តែងចំពោះ សណ្តាប់ធ្នាប់សាធារណៈដែលអាចបណ្តាលឲ្យសាធារណៈជនមានទស្សនៈអវិជ្ជមាន ចំពោះការដោះលែងដែលគេបានដឹងរបស់លោក **អៀង សារី** ។ ដោយមិនបានពិចារណាចំពោះ ការវិភាគថ្មីៗចំពោះការគម្រាមកំហែងចំពោះសណ្តាប់ធ្នាប់សាធារណៈ ក.ស.ច.ស បាន ទទួលយកដោយងាយៗនូវសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ និងបានរកឃើញថា ការដោះលែងលោក **អៀង សារី** នឹងពិតជារំខានសណ្តាប់ធ្នាប់សាធារណៈមែនដោយ បង្ហាញយ៉ាងងាយៗថា មិនមានភស្តុតាងដែលបង្ហាញថា ស្ថានការណ៍បានផ្លាស់ប្តូរ ចាប់តាំងពីមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះមក[71]។ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា របបកម្ពុជាប្រជាធិបតេយ្យនៅតែមានផលប៉ះពាល់ ទៅលើប្រជាពលរដ្ឋ និងមនុស្សជាច្រើននៅតែរងនូវការបាក់ស្បាត និង តឹងតែងផ្លូវចិត្ត នៅឡើយ។ អង្គបុរេជំនុំជម្រះ ថែមទាំងប្រកាន់ជំហរថា ការជំនុំជម្រះនាពេលខាងមុខនឹងបង្កឲ្យកើតមាននូវកំហឹង និងផលវិបាកជាអវិជ្ជមានក្នុងសង្គម។ ក.ស.ច.ស បានទទួលស្គាល់នូវការគម្រាមកំហែង "ដ៏ពិតប្រាកដ" ដូចដែលបានរៀបរាប់ដោយអង្គបុរេជំនុំជម្រះ។

៥៩. អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំក្នុងការពឹងផ្អែកទៅលើរបាយការណ៍ខ្លះដែលខ្លួនបាន ពណ៌នានៅក្នុងសេចក្តីសម្រេចអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ របាយការណ៍មួយបាន ពណ៌នាអំពីការប្រឆាំងដ៏ចម្លែករបស់សាធារណៈជនដែលបានកើតឡើងនៅក្នុងឆ្នាំ ២០០៣ នៅពេលដែលប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថា តារាសម្តែងថៃម្នាក់បានអះអាងថា ប្រាសាទអង្គរវត្តគឺជារបស់ប្រទេសថៃ[72]។ ជាការពិតលោក **អៀង សារី** មិនមែនជាតារាសម្តែងថៃម្នាក់នោះទេ ក្នុងន័យស្រដៀងគ្នានេះជាមួយនឹងការប្រឆាំងរបស់សាធារណៈជនចំពោះបទអត្ថាធិប្បាយរបស់តារាសម្តែងរូបនោះ គឺពិតប្រាកដណាស់មានតម្លៃកម្រិតរបស់វា។ ក.ស.ច.ស និង អង្គបុរេជំនុំជម្រះបានពឹងផ្អែកដោយភ័ន្តច្រឡំលើភ័ស្តុតាង កាលពីជាង ៥ឆ្នាំមុន។ ការអភិវឌ្ឍន៍ដ៏លឿនដែលមិនគួរឲ្យជឿនៅក្នុងប្រទេសកម្ពុជា តម្រូវឲ្យមានការពិនិត្យជាថ្មីអំពីការគម្រាមកំហែងចំពោះសណ្តាប់ធ្នាប់សាធារណៈរៀងរាល់ពេលដែល ក.ស.ច.ស ពិចារណាឃើញថា តើការឃុំខ្លួនបណ្តោះអាសន្នជាការចាំបាច់ ឬ

---

[71] ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៣១។

[72] សេចក្តីសម្រេចលើបណ្តឹង ឧទ្ធរណ៍ស្តីពីការឃុំខ្លួន លេខយោង ៧០។

យ៉ាងណា។ របាយការណ៍ជាច្រើននាពេលថ្មីៗនេះបានបង្ហាញដោយគ្មានមន្ទិលថា ស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា គឺពិតជាមានស្ថេរភាព និងសន្តិភាពច្រើនហួសប្រមាណពិតប្រាកដមែន[73]។ ក.ស.ច.ស គួរតែពិចារណាអំពីរបាយការណ៍នៃព័ត៌មានថ្មីៗដែលបានពណ៌នាថា ទោះបីជាមានរបាយការណ៍រីករាលដាលអំពីភាពមិនប្រក្រតីក៏ដោយ ក៏ការបោះឆ្នោតជាតិដែលបានរៀបចំឡើងនាពេលថ្មីៗក្នុងឆ្នាំនេះប្រកបដោយសន្តិភាពស្ទើរទូទាំងប្រទេស[74] ឬសេចក្តីរាយការណ៍អំពីសណ្តាប់ធ្នាប់សាធារណៈដែលមានការរីកចម្រើននៅក្នុងអំឡុងពេលនៃពិធីបុណ្យអុំទូក នាពេលថ្មីៗនេះក៏ដោយ[75]។ របាយការណ៍បែបនោះបង្ហាញថា ការគម្រាមកំហែងចំពោះសណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីការកែប្រែលក្ខខណ្ឌនៃការឃុំខ្លួនបុរសអាយុ ៨៣ឆ្នាំម្នាក់ គឺបច្ចុប្បន្ននេះមិនមានទៀតទេ។ វិធាន ៦៣(៦)(ក) ដែលតម្រូវឲ្យមានការពិនិត្យឡើងវិញជាទៀងទាត់នូវភាពចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន បានបង្ហាញយ៉ាងច្បាស់ថា ហានិភ័យចំពោះសណ្តាប់សាធារណៈ ត្រូវតែធ្វើការវាយតម្លៃដោយផ្អែកលើភស្តុតាងនៃស្ថានការណ៍នៅក្នុងសង្គមនៅពេលធ្វើសេចក្តីសម្រេចអំពីការឃុំខ្លួន ជាជាងពឹងផ្អែកលើរបាយការណ៍ចាស់ៗ និងហួសសម័យ។

៥០. ក.ស.ច.ស ថែមទាំងបានខកខានមិនបានពិចារណាថា តើមានទម្រង់នៃការឃុំខ្លួនដែលមាន ការកំហិតតិច ដូចជាការឃុំខ្លួននៅក្នុងផ្ទះ ដែលនឹងបង្កហានិភ័យស្មើគ្នាចំពោះសណ្តាប់ធ្នាប់សាធារណៈ ឬមួយយ៉ាងណា។ សំខាន់ជាងនេះទៅទៀត ក.ស.ច.ស មិនបានពិចារណាអំពីអ្វីដែលតុលាការទាំងមូលអាចធ្វើបានដើម្បីធានាថា ហានិភ័យបែបនោះមិនបានកើតឡើងទេ។

---

[73] ដោយពិចារណាចំពោះសុន្ទរកថាឆ្នាំ ២០០៧ ដែលបានធ្វើដោយនាយករដ្ឋមន្ត្រីហ៊ុន សែន ឬរបាយការណ៍អភិវឌ្ឍធនធានមនុស្សរបស់ប្រទេសកម្ពុជា ២០០៧ ឬរបាយការណ៍ ២០០៧របស់ធនាគារពិភពលោក ដែលបានរៀបរាប់នៅក្នុង*សំណុំរឿងរបស់ អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣) ដីកាសម្រេចអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់អៀង សារី ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៨ កថាខណ្ឌ ៧-២១។

[74] សារព័ត៌មានភ្នំពេញប៉ុស្ត៍ *ការបោះឆ្នោតឆ្នាំ ២០០៨ មានសន្តិភាព ក៏ប៉ុន្តែមានកំហុស៖ អ្នកសង្កេតការណ៍អឺរ៉ុប* ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៨។

[75] សារព័ត៌មានភ្នំពេញប៉ុស្ត៍ *ទីក្រុងភ្នំពេញបញ្ចប់ពិធីបុណ្យជាតិមួយទៀត* ថ្ងៃសុក្រ ទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ “ប្រជាជនដែលចូលរួមសប្បាយក្នុងពិធីបាននិយាយថា មានសណ្តាប់ធ្នាប់សាធារណៈដ៏ប្រសើរជាងនេះសម្រាប់ពិធីដ៏គួរឲ្យចងចាំមួយនេះ”។

៥១. ប្រសិនបើត្រូវបានពន្យល់ឲ្យបានច្បាស់លាស់ដោយផ្នែកផ្សព្វផ្សាយដ៏ទូលំទូលាយ និងទំនាក់ទំនងសាធារណៈរបស់ អ.វ.ត.ក ថាការឃុំខ្លួននៅក្នុងផ្ទះគឺជាទម្រង់នៃការឃុំខ្លួនមួយ ហើយ ក្នុងទិដ្ឋភាពជាច្រើន វាមិនខុសប្លែកពីការឃុំឃាំងនៅក្នុងពន្ធនាគារនោះទេ ហើយគ្មានការគម្រាមកំហែងចំពោះសណ្តាប់ធ្នាប់សាធារណៈអាចកើតមានឡើងនោះទេ។ ផ្ទុយមកវិញ ក.ស.ច.ស ហាក់ដូចជាចូលចិត្តពឹងផ្អែកលើការភ័ន្តច្រឡំរបស់សាធារណៈជនអំពីការឃុំខ្លួននៅក្នុងផ្ទះ ដើម្បីយកមកធ្វើការបដិសេធនូវជម្រើសនេះចំពោះលោក **អៀង សារី**។ សិទ្ធិរបស់លោក **អៀង សារី** មិនគួរត្រូវបាត់បង់ការយល់ខុសរបស់សាធារណៈជនអំពីបញ្ហា យុត្តិធម៌ នោះទេ ។ អ.វ.ត.ក ត្រូវមានភារកិច្ចក្នុងការនាំយកវិធានការយុត្តិធម៌មួយចំនួន មកអនុវត្តនៅក្នុងកិច្ចដំណើរការតុលាការរបស់កម្ពុជា។ យុត្តិធម៌ "ក៏មានន័យផងដែរថា ជាការគោរពចំពោះសិទ្ធិជាសារវន្តរបស់ជនដែលគេចោទប្រកាន់ថាជាជនល្មើសផងដែរ"[76]។

## V. សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥២. ការស៊ើបអង្កេតរបស់ ក.ស.ច.ស ក្នុងសំណុំរឿងលោក **អៀង សារី** ត្រូវបានធ្វើឡើងដោយ មិនមានការយកចិត្តទុកដាក់ ឬគិតគូរអំពីរបៀបដែលថា ការឃុំខ្លួនបណ្តោះអាសន្ននឹងបណ្តាលឲ្យមានការប៉ះពាល់ជៀសមិនផុតចំពោះបញ្ហាស្ថានភាពសុខភាពផ្លូវចិត្ត និងផ្លូវកាយដែលកំពុងទ្រុឌទ្រោមរួចទៅហើយរបស់លោក **អៀង សារី**។ ដោយពឹងផ្អែកលើ ជាជាងការកែតម្រូវ ការរំលោភបំពានចំពោះសិទ្ធិមានសេរីភាព និងសិទ្ធិនៅស្ងៀមដែលជាសិទ្ធជាសារវន្តរបស់លោក **អៀង សារី** ក.ស.ច.ស បានបង្ហាញនូវចេតនានៃការមិនគោរពបទដ្ឋានជាតិ និងអន្តរជាតិអំពីសិទ្ធិមនុស្សដែល អ.វ.ត.ក មានកតព្វកិច្ចត្រូវលើកស្ទួយ។ លោក **អៀង សារី** ត្រូវបានសន្មតជាមុនថាគ្មានពិរុទ្ធ តែត្រូវបានបង្ខំឲ្យបោះបង់សិទ្ធិរបស់គាត់ក្នុងឆ្នាំទី២ ក្នុងវ័យចំណាស់អាយុ ៨៣ឆ្នាំរបស់គាត់

---

[76] *ព្រះរាជអាជ្ញា ទល់នឹង Hadzihasanovic et al.*"IT-01-47 សេចក្តីសម្រេចអនុញ្ញាតិឲ្យមានការដោះលែងបណ្តោះអាសន្នចំពោះ Enver Hadzihasanovic ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០១ កថាខណ្ឌ ៥។

ដោយសង្ឃឹមថា ការចោទប្រកាន់អាចនឹងត្រូវបានធ្វើប្រឆាំងនឹងគាត់នៅពេលណាមួយក្នុងពេលអនាគតខាងមុខ។

៥៣. ការដាក់លោក **អៀង សារី** នៅក្រោមលក្ខខណ្ឌនៃការឃុំខ្លួនក្នុងផ្ទះនឹងអាចជួយទូទាត់ចំពោះភាពមិនគ្រប់គ្រាន់នៃការស៊ើបសួររបស់ ក.ស.ច.ស ហើយនឹងអាចឆ្លើយតបទៅនឹងគោលបំណងនៃវិធាន ៦៣(៣)(ខ)។ ករណីនៃការឃុំខ្លួននៅក្នុងផ្ទះ គឺត្រូវធ្វើដោយបង្ខំដោយយោង លើស្ថានភាពអាយុ និងសុខភាពមិនល្អរបស់លោក **អៀង សារី** ដែលជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះក្នុងការអនុវត្តនូវឆន្ទានុសិទ្ធដែលអនុញ្ញាតិដោយវិធាន ៦៣(៣) និងបង្គាប់ឲ្យដោះលែងលោក **អៀង សារី** នៅក្រោមលក្ខខណ្ឌដែលមានកំហិតតិចនៃការឃុំខ្លួននៅក្នុងផ្ទះ[77]។

ដូច្នេះ យោងតាមហេតុផលដូចដែលបានគូសបញ្ជាក់មកនេះ មេធាវីការពារក្តីសូមស្នើ ដោយសេចក្តីគោរពដល់អង្គបុរេជំនុំជម្រះ៖

ក. **ទុកជាមោឃៈ** នូវដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចេញនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបង្គាប់ឲ្យមានការដោះលែងលោក **អៀង សារី** ជាបណ្តោះអាសន្ន ឬ

ខ. **បង្គាប់** ឲ្យ ក.ស.ច.ស កែតម្រូវលក្ខខណ្ឌនៃការឃុំខ្លួនស្របតាមវិធាន ៦៣(៨) និងអនុញ្ញាតិឲ្យមានលក្ខខណ្ឌឃុំខ្លួននៅក្នុងផ្ទះដូចដែលបានពណ៌នា ខាងលើ។

---

[77] យុត្តិសាស្ត្រពីសាលាក្តីផ្សេងទៀតបានបង្ហាញថា អាយុ និងលក្ខខណ្ឌវេជ្ជសាស្ត្ររបស់ជនជាប់ចោទអាចបង្ហាញ "នូវកត្តាដែលលេចចេញ និងពាក់ព័ន្ធនៅក្នុងការវាយតម្លៃថាតើត្រូវអនុវត្តឆន្ទានុសិទ្ធិដើម្បីអនុញ្ញាតិឲ្យមានការដោះលែងបណ្តោះអាសន្នឬមួយ យ៉ាងណា" *ព្រះរាជអាជ្ញា ទល់នឹង Jovica Stanisic* IT-03-69-PT សេចក្តីសម្រេចអំពីការដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៤១។ សូមអានផងដែរ ករណីតុលាការសិទ្ធិមនុស្សអឺរ៉ុបនៃ *Kudla ទល់នឹង ប្រទេសប៉ូឡូញ* ពាក្យសុំ លេខ ៣០២១០/៩៦ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០០ កថាខណ្ឌ ១៣០៖ "អ្នកដាក់ពាក្យសុំបានស្ថិតនៅក្នុងកន្លែងឃុំឃាំង និងបានរងទុក្ខលំបាកយ៉ាងធ្ងន់ធ្ងរ។ ការណ៍នេះតម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេសរបស់ពួកគេក្នុងការដោះស្រាយករណីរបស់គាត់"។

C22/5/1

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ )

សូមដាក់ជូនដោយសេចក្តីគោរព

MEDHAVI AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

.............................................................................................................

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

ហត្ថលេខាក្នុងទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០៨